**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# ការរៀបចំទីក្រុងឆ្លាតវៃនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ

និស្សិតឈ្មោះៈ លោក **ពិសិដ្ឋ ពិសើរ**

លោក **មាស កែវទីរៈបុត្រ**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេររបាយការណ៍ ២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ ឈ្មោះ **ពិសិដ្ឋ ពិសើរ** និង **មាស កែវវីរៈបុត្រ** ជានិស្សិតនៃសាលកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រុម L2A4 ជំនាន់ទី២០ ផ្នែកនីតិសាស្ត្រ ឆ្នាំសិក្សា ២០១៦-២០២០។

## សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ

មាតិបិតាដែលជាអ្នកមានគុណដ៏ថ្លៃថ្លា ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ហើយផ្តល់នូវការអប់រំយ៉ាងច្រើនប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងទូន្មានប្រៀនប្រដៅកូនឱ្យក្លាយជា កូនល្អ សិស្សល្អ មិត្តល្អ និងជាបុគ្គលល្អក្នុងសង្គម។ មិនតែប៉ុណ្ណោះ លោកទាំងពីរបានផ្គត់ផ្គង់សម្ភារៈ និងឱកាសឱ្យយើងខ្ញុំទាំងពីរបានសិក្សារៀនសូត្រ ដើម្បីក្រេបជញ្ជក់យកចំណេះដឹង ចំណេះធ្វើ ដើម្បីក្លាយខ្លួនជាបុគ្គលដែលតម្លៃសម្រាប់ខ្លួនឯង គ្រួសារ និងសង្គមជាតិទាំងមូល។

ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរសរងនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាត និងផ្តល់លទ្ធភាពឱ្យយើងខ្ញុំទាំងពីរទទួលបាននូវឱកាសក្នុងការចូលសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ លោក លោកស្រី ដែលជាសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន ណែនាំ និងផ្តល់នូវចំណេះដឹងដល់យើងខ្ញុំទាំងពីរអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ព្រមទាំងផ្តល់នូវដំបូន្មានពាក្យអប់រំប្រដៅ និងទស្សនទានល្អៗជាច្រើនសម្រាប់ការសិក្សា និងការអភិវឌ្ឍខ្លួនក្លាយទៅជាបុគ្គលដែលមានសមត្ថភាពមួយរូបក្នុងសង្គម ។

លោកសាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំផ្តល់ជាយោបល់ល្អៗ និងជួយកែសម្រួលនូវសារណាមួយនេះចាប់ពីផ្តើមរហូតដល់បញ្ចប់នូវសៀវភៅមួយក្បាលនេះបានជោគជ័យ។ ជាពិសេសរៀមច្បងជំនាន់មុនដែលបានបន្សល់ទុកនូវស្នាដៃល្អៗ ដែលជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយយកមកធ្វើជាគំរូ និងសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ។

ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់ សូមធ្វើការដឹងគុណដល់មាតាបិតា ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកទាំងអស់ដែលកំពុងបំពេញការងារនៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ជួបប្រទះតែសេចក្តីសុខ ព្រមទាំងពុទ្ធពរទាំងបួនប្រការគឺ អាយុវណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បើយើងក្រឡេកមើលទៅស្ថានភាពទីក្រុងនៅលើពិភពលោកក្នុងពេលបច្ចុប្បន្ន បានបង្ហាញឱ្យឃើញថា កំពុងតែមានការប្រែប្រួលទីក្រុងយ៉ាងខ្លាំង ដោយប្រទេសនីមួយៗកំពុងព្យាយាមអភិវឌ្ឍខ្លួនទៅជាទីក្រុងទំនើប មានសក្ដានុពល និងមានភាពរីកចម្រើនកាន់តែខ្លាំង។ ជាក់ស្ដែង ប្រទេសកម្ពុជាដែលជាសមាជិកអាស៊ានក៏បានរួមបញ្ចូលទិសដៅនៃការបង្កើតទីក្រុងឆ្លាតវៃជាមួយបណ្ដាប្រទេសនៅអាស៊ានទាំងមូល។ ការរួមគំនិតជាមួយបណ្ដាប្រទេសនៅអាស៊ានរបស់ប្រទេសកម្ពុជា ក៏ទាមទារឱ្យប្រទេសធ្វើការអភិវឌ្ឍនូវវិស័យមួយចំនួនដូចជា វិស័យអប់រំ និងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជាមុនសិន ដើម្បីអភិវឌ្ឍវិស័យផ្សេងៗទៀតក្នុងប្រទេសជាតិ។ យ៉ាងណាមិញ ក្នុងការអភិវឌ្ឍប្រទេសខ្លួនឱ្យក្លាយជាទីក្រុងឆ្លាតវៃមួយនៅតំបន់អាស៊ាន ដូច្នេះតម្រូវឱ្យប្រជាពលរដ្ឋគ្រប់រូបសហការគ្នា និងជួយជម្រុញអភិវឌ្ឍប្រទេសជាតិខ្លួនឱ្យទទួលបានភាពស៊ីវិល័យ។

ដោយប្រទេសកំពុងមានការអភិវឌ្ឍ បានជម្រុញឱ្យវិស័យសំណង់មានការលូតលាស់យ៉ាងខ្លាំងគ្រប់បណ្ដារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ក្នុងនោះដែរ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ធ្វើយ៉ាងណាប្រែក្លាយទីក្រុងនៅកម្ពុជាជាទីក្រុងបៃតង មានបរិស្ថានស្អាត មានផលប៉ះពាល់កំរិតទាប និងជាមជ្ឈមណ្ឌលពាណិជ្ជកម្ម សេដ្ឋកិច្ច វប្បធម៌ ដែលមានលក្ខណៈប្រកួតប្រជែងរបស់ប្រទេសកម្ពុជានឹងការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌។

ដោយយើងខ្ញុំជឿជាក់ថា យើងអាចប្រែក្លាយទីក្រុងនៅកម្ពុជាមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព ហើយតាមរយៈការរៀបចំផែនការនេះ យើងក៏អាចរួមចំណែកដោះស្រាយនូវបញ្ហាប្រែប្រួលអាកាសធាតុ ស្របពេលដែលយើងកំពុងខិតខំបន្តអភិវឌ្ឍសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ ពង្រឹងការអភិវឌ្ឍ និងបរិយាប័ន្នសង្គមផងដែរ ទើបក្រុមយើងខ្ញុំធ្វើការស្រាវជ្រាវក្រោមប្រធានបទមួយដែលស្ដីពី “**ការរៀបចំទីក្រុងឆ្លាតវៃនៅកម្ពុជា**” ។

ជាចុងក្រោយ ទោះបីឆ្លងកាត់ដំណាក់កាលត្រួតពិនិត្យ និងកែសម្រួលជាច្រើនដំណាក់កាលក៏ដោយ ក៏យើងខ្ញុំប្រាកដជានៅមានចំណុចខ្វះខាតកើតមានឡើង។ ដូច្នេះហើយយើងខ្ញុំទាំងពីរ សូមធ្វើការអភ័យទោសកំហុសដែលបានកើតឡើងដោយអចេតនា ហើយយើងខ្ញុំមានសេចក្ដីសមនោសរីករាយក្នុងការទទួលការរិះគន់ក្នុងន័យស្ថាបនា ដើម្បីកែសម្របន្ថែមឆ្ពោះទៅរកការបង្កើនគុណភាពនិងសុក្រឹតភាពនៃសារណានេះ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**សញ្ញាណនៃការរៀបចំក្រុង**

**១.១. ទិដ្ឋភាពទូទៅនៃការរៀបចំក្រុង** ........ ៣

**១.១.១. បរិបទទូទៅនៃការរៀបចំក្រុង** ........ ៣

១.១.១.១. និយមន័យ ........ ៣

១.១.១.២. ប្រវត្តិនៃការរៀបចំទីក្រុងដំបូងនៃសកលលោក ........ ៣

១.១.១.៣. ការវិវត្តន៍ទីក្រុងនៅកម្ពុជា ........ ៤

**១.១.២. បុព្វហេតុនាំឱ្យមានការរៀបចំក្រុង** ........ ៥

១.១.២.១. កំណើនប្រជាជន ........ ៥

១.១.២.២. ភាពក្រីក្រ ........ ៥

១.១.២.៣. កម្រិតជីវភាពរស់នៅ ........ ៥

១.១.២.៤. ការដាក់សម្ពាធបរិស្ថាន ........ ៦

**១.២. ការរៀបចំក្រុងឱ្យមានសោភ័ណ្ឌភាព និងសណ្តាប់ធ្នាប់** ........ ៦

**១.២.១. សោភ័ណ្ឌភាព** ........ ៦

១.២.១.១. ពេលថ្ងៃ ........ ៦

១.១.១.២. ពេលយប់ ........ ១០

**១.២.២. សណ្តាប់ធ្នាប់** ........ ១០

១.២.២.១. សន្តិសុខ ........ ១១

១.២.២.២. ភាពស្ងប់ស្ងៀម ........ ១៣

១.២.២.៣. អនាម័យ ........ ១៣

**១.២.៣. ទីក្រុងគ្មានការបំពុលទាំង៥** ........ ១៣

១.២.៣.១. គ្មានការបំពុលទឹក ........ ១៣

១.២.៣.២. គ្មានការបំពុលខ្យល់ ........ ១៤

១.២.៣.៣. គ្មានការបំពុលដី ........ ១៥

១.២.៣.៤. គ្មានការបំពុលដោយសារសំណល់រឹងរាវ ........ ១៦

១.២.៣.៥. គ្មានការបំពុលដោយសម្លេង ........ ១៧

## ជំពូកទី២
## ការរៀបចំទីក្រុងឆ្លាតវៃនៅកម្ពុជា


**២.១. ជំហានដំបូងឈានទៅរកការរៀបចំទីក្រុងឆ្លាតវៃនៅកម្ពុជា** .................. ១៩

**២.១.១. ការរៀបចំប្លង់គោល** .................. ១៩

២.១.១.១. សញ្ញាណទូទៅនៃការរៀបចំប្លង់គោល .................. ១៩

២.១.១.២. អត្ថប្រយោជន៍នៃប្លង់គោល .................. ២០

២.១.១.៣. ឯកសារចំបងក្នុងនីតិនគរូបនីយវិទ្យា .................. ២១

**២.១.២. ការរៀបចំផែនការសម្រាប់ទីក្រុងឆ្លាតវៃនៅកម្ពុជា** .................. ២៧

២.១.២.១. ចរាចរណ៍ឆ្លាតវៃ .................. ២៧

២.១.២.២. ភ្លើងបំភ្លឺផ្លូវឆ្លាតវៃ .................. ២៨

២.១.២.៣. ចំណតឆ្លាតវៃ .................. ២៨

២.១.២.៤. ប្រព័ន្ធកាមេរ៉ាឆ្លាតវៃ .................. ២៨

២.១.២.៥. ការគ្រប់គ្រងកាកសំណល់ឆ្លាតវៃ .................. ២៩

**២.១.៣. ហេដ្ឋារចនាសម្ព័ន្ធនៃសំណង់** .................. ៣០

២.១.៣.១. ទំនើបកម្មនៃសំណង់ .................. ៣០

២.១.៣.២.ប្រណិតភាពនៃហេដ្ឋារចនាសម្ព័ន្ធ .................. ៣០

២.១.៣.៣. ប្រណិតភាពនៃទំនើបកម្មសម្រាប់ការរស់នៅ .................. ៣១

**២.២. អនាគតទីក្រុងឆ្លាតវៃនៅកម្ពុជា** .................. ៣១

**២.២.១. និន្នាការទៅរកទីក្រុងឆ្លាតវៃ** .................. ៣១

**២.២.២. គម្រោងរៀបចំទីក្រុងឆ្លាតវៃនៅកម្ពុជា** .................. ៣២

**២.២.៣. ភាពអវិជ្ជមាននៃទីក្រុងឆ្លាតវៃ** .................. ៣៣

**២.២.៤. ដំណោះស្រាយ** .................. ៣៤

**សេចក្តីសន្និដ្ឋាន** .................. ៣៥

**អនុសាសន៍** .................. ៣៦

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នាពេលបច្ចុប្បន្ននេះ តាមបណ្ដាប្រទេសនីមួយៗនៅលើសកលលោក មានសកម្មភាពជាច្រើនក្នុងការអភិវឌ្ឍប្រទេសរបស់ខ្លួនឱ្យកាន់តែរីកចម្រើនក៏ដូចជានៅក្នុងប្រទេសកម្ពុជាផងដែរ។ យ៉ាងណាមិញ ប្រទេសកម្ពុជាក្រោយរំដោះចេញពីរបបខ្មៅងងឹត ០៣ឆ្នាំ ០៨ខែ និង២០ថ្ងៃ (របបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីឆ្នាំ១៩៧៥ ដល់ ១៩៧៩) ព្រមទាំងមានការចរចាបង្រួបបង្រួមគ្នាឡើងវិញរវាងខ្មែរ និងខ្មែរ នាថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩១ រហូតឈានដល់ការបោះឆ្នោតសារឡើងវិញ ដែលបានរៀបចំឡើងដោយអង្គការសហប្រជាជាតិឆ្នាំ១៩៩៣ រួចមកប្រទេសកម្ពុជាបានរៀបចំកសាងប្រទេសឡើងវិញ ចាប់តាំងពីបាតដៃទទេរហូតដល់មានការអភិវឌ្ឍលើគ្រប់វិស័យនាពេលបច្ចុប្បន្ននេះ។ ដូច្នេះការចាប់ផ្ដើមកសាងហេដ្ឋារចនាសម្ព័ន្ធឡើងវិញជាកត្តាសំខាន់ដោយផ្ដើមរៀបចំរាជធានី ក្រុង ស្រុក ឃុំ សង្កាត់ សារជាថ្មី វាពិតជាមានផលលំបាកយ៉ាងខ្លាំង ហើយរាជរដ្ឋាភិបាលបានខិតខំរៀបចំទីក្រុងនៅក្នុងប្រទេសកម្ពុជាឱ្យមានភាពស៊ីវិល័យ។ បន្ថែមពីនេះទៅទៀត តាមរយៈការលូតលាស់ទៅមុខឥតឈប់ឈរលើវិស័យសំណង់ ហើយវិស័យមួយនេះបានលូតលាស់យ៉ាងខ្លាំង និងអភិវឌ្ឍទៅមុខយ៉ាងសកម្ម។ វិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងទំនើបឆ្លាតវៃ ដែលជាគោលការណ៍ណែនាំជាជំហានៗសម្រាប់មន្ត្រីពាក់ព័ន្ធនានាទាំងនៅរាជធានី ក្រុង ស្រុក ឃុំ សង្កាត់ ព្រមទាំងភាគីពាក់ព័ន្ធនៃទីក្រុងនៅព្រះរាជាណាចក្រកម្ពុជាដែលកំពុងបន្តអនុវត្តដំណើរការអភិវឌ្ឍទីក្រុងរបស់ខ្លួន សំដៅឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព។ វិធីសាស្ត្រនេះគាំទ្រដល់ទីក្រុងនានាក្នុងការសិក្សាវាយតម្លៃ និងកំណត់អាទិភាពអភិវឌ្ឍនិរន្តរភាព (គម្រោងវិនិយោគ និងកំណែទម្រង់គោលនយោបាយ) សម្រាប់អនុវត្ត។ វិធីសាស្ត្រនេះបានពិចារណាយ៉ាងគ្រប់ជ្រុងជ្រោយទៅលើគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍទីក្រុងនិរន្តភាព ក៏ដូចជាការអភិវឌ្ឍដែលបំភាយកាបូនិក ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការប្រើប្រាស់ប្រសិទ្ធភាពធនធានព្រមទាំងបរិយាប័ន្នសង្គម និងការកាត់បន្ថយភាពក្រីក្រ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទខាងលើត្រូវធ្វើឡើងដោយឆ្លើយតបនឹងសំណួរដូចខាងក្រោម៖

១. មូលហេតុចំបងអ្វីខ្លះដែលនាំឱ្យមានការរៀបចំក្រុង?

២. តើត្រូវធ្វើដូចម្ដេចទើបអាចរៀបចំក្រុងឱ្យមានសណ្ដាប់ធ្នាប់ សោភ័ណ្ឌភាព ដើម្បីមានលទ្ធភាពឈានទៅរកការបង្កើតទីក្រុងឆ្លាតវៃបាន?

៣. តើអ្វីទៅជាជំហានដំបូងនៃការរៀបចំក្រុងឆ្លាតវៃនៅកម្ពុជា?

៤. អ្វីទៅជា **«ទីក្រុងឆ្លាតវៃ»?** តើគម្រោងទីក្រុងឆ្លាតវៃត្រូវបង្កើតឡើងនៅពេលណា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវរបស់យើងខ្ញុំមានគោលបំណងចង់ឱ្យមិត្តនិស្សិត មិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវ និងសាធារណជនទាំងអស់ ដោយផ្តោតទៅលើផែនការយុទ្ធសាស្ត្រនានាដែលចាត់តាំងពីការកកើតក្រុងដំបូងរហូតក្លាយទៅជាទីក្រុង និងវិវត្តន៍ទៅទីក្រុងឆ្លាតវៃ ព្រមទាំងចង់បង្ហាញពីការអភិវឌ្ឍរបស់ប្រទេសកម្ពុជានាពេលខាងមុខផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានទំហំ និងដែនកំណត់ច្បាស់លាស់របស់ខ្លួន។ ចំពោះការសិក្សាស្រាវជ្រាវលើប្រធានបទដែលទាក់ទងទៅនឹង **"ការរៀបចំក្រុងឆ្លាតវៃនៅប្រទេសកម្ពុជា"** គឺយើងសិក្សាស្រាវជ្រាវទៅលើទិដ្ឋភាពជាក់ស្តែងព្រមទាំងឯកសារពាក់ព័ន្ធ និងលិខិតបទដ្ឋានគតិយុត្តនានាដែលទាក់ទងការវិវត្តន៍ទីក្រុងឱ្យទៅជាទីក្រុងទំនើបមួយនៅតំបន់អាស៊ាន។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះពិតជាបានចូលរួមចំណែកមួយយ៉ាងសំខាន់ ជាពិសេសបានផ្តល់នូវពុទ្ធិដល់មិត្តនិស្សិត មិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវ និងសាធារណជនទាំងអស់ឱ្យយល់ដឹងកាន់តែស៊ីជម្រៅអំពីការរៀបចំផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍទីក្រុងនៅកម្ពុជាទៅជាទីក្រុងឆ្លាតវៃ ដើម្បីធ្វើយ៉ាងណាដើរឱ្យទាន់តាមបណ្តាប្រទេសជិតខាង ព្រមទាំងប្រែក្លាយទីក្រុងនៅកម្ពុជាឱ្យកាន់តែមានភាពរីកចម្រើនបន្ថែមទៀតនាពេលខាងមុខ និងនាពេលអនាគត។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវលើប្រធានបទ **"ការរៀបចំទីក្រុងឆ្លាតវៃនៅកម្ពុជា"** គឺក្រុមយើងខ្ញុំបានធ្វើការសិក្សាស្វែងយល់ពីឯកសារពាក់ព័ន្ធនានា នៅតាមបណ្ណាល័យផ្សេងៗជាពិសេសបណ្ណាល័យនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច តាមស្ថាប័ន អង្គភាពនានា និងតាមរយៈប្រព័ន្ធអ៊ីនធឺណិត ដោយក្នុងនោះយើងខ្ញុំបានប្រមូលផ្តុំឯកសារទាំងនោះបន្ទាប់មកសិក្សា ពិភាក្សា និងវិភាគ ព្រមទាំងចុះរកទិន្នន័យជាក់ស្តែងនៅតាមបណ្តាស្ថាប័ន អង្គភាពពាក់ព័ន្ធនឹងគម្រោងនៃការរៀបចំក្រុងឆ្លាតវៃនេះផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ យើងខ្ញុំបានកំណត់បែងចែកសកម្មភាពតាមដំណាក់កាលនីមួយៗដូចតទៅៈ

- **ជំពូកទី១ សញ្ញាណនៃការរៀបចំក្រុង ៖** ក្នុងជំពូកនេះនិយាយអំពីទិន្នភាពទៅនៃការរៀបចំក្រុង និងការរៀបចំក្រុងឱ្យមានសោភ័ណ្ឌភាព និងសណ្តាប់ធ្នាប់។
- **ជំពូកទី១ ការរៀបចំទីក្រុងឆ្លាតវៃនៅកម្ពុជា** ក្នុងជំពូកនេះបរិយាយអំពីជំហានដំបូងឈានទៅរកការរៀបចំទីក្រុងឆ្លាតវៃនៅកម្ពុជា និងអនាគតទីក្រុងឆ្លាតវៃនៅកម្ពុជា។

# ជំពូកទី១
# សញ្ញាណនៃការរៀបចំក្រុង

# ជំពូកទី១

# សញ្ញាណនៃការរៀបចំក្រុង

## ១.១. ទិដ្ឋភាពទូទៅនៃការរៀបចំក្រុង

### ១.១.១. បរិបទទូទៅនៃការរៀបចំក្រុង

#### ១.១.១.១. និយមន័យ

ជាការពិតណាស់ការរៀបចំក្រុងមួយចាំបាច់ត្រូវធ្វើឡើង ដោយគិតគូរយ៉ាងហ្មត់ចត់សព្វគ្រប់ជ្រុងជ្រោយ ហើយការរៀបចំនេះពុំមែនជាភាពចៃដន្យនោះទេ ពោលគឺមានកត្តាជាច្រើនដែលជួយជំរុញឱ្យមានការរៀបចំក្រុង។ ចំណែកនិយមន័យទីក្រុង សំដៅដល់ទីកន្លែងមួយដែលមិនមានសកម្មភាពកសិកម្ម។ លក្ខណៈវិនិច្ឆ័យផ្សេងទៀតអាចរួមបញ្ចូលៈ ចំនួនប្រជាជន, ទីធ្លាទំនេរ, ដង់ស៊ីតេ, ប្រជាជន, និងចរន្តសេដ្ឋកិច្ច។[១]

#### ១.១.១.២. ប្រវត្តិនៃការរៀបចំទីក្រុងដំបូងនៃសកលលោក

Faiyum (ជនជាតិអេហ្ស៊ីបភាសាអារ៉ាប់ហៅថា el-Fayyum) គឺជាទីក្រុងមួយដែលនៅចំកណ្ដាលប្រទេសអេហ្ស៊ីបមានចម្ងាយ ១០០គីឡូម៉ែត (៦២ម៉ាយ) ពីទិសខាងត្បូងឆៀងខាងលិចនៃទីក្រុង cario។ មួយផ្នែកនៃទីក្រុងនេះត្រូវបានចូលត្រួតត្រាដោយសម័យកាល Crocodilopolish ឬ Arsinoe បុរាណ។

ឈ្មោះរបស់ទីក្រុងនេះជាភាសាអង់គ្លេសគឺប្រកបថា Fayum, Fayoum, Al Fayum ឬ El Faiyum. Faiyum ដែលកាលពីមុនត្រូវបានគេដាក់ឈ្មោះជាផ្លូវការថា Madinet el Faiyum (ភាសាអារ៉ាប់) ការប្រកបឈ្មោះ Faiyum ត្រូវបានធ្វើការផ្លាស់ប្ដូរជារឿយៗ ហើយជាទូទៅវាក៏ត្រូវបានប្រើប្រាស់ដោយប្រជាជនអេហ្ស៊ីបនៅក្នុងក្រុងផងដែរ។ ឈ្មោះទីក្រុងទំនើបដែលទទួលបានមកពី Coptic efiom/Peiom (ដូច្នេះឈ្មោះត្រឹមត្រូវគឺPayom) មានន័យថាសមុទ្រ ឬបឹងដែលចេញមកពីប្រជាជនអេហ្ស៊ីប។ លុះសម័យកាលក្រោយមក Pay-m គឺមានអត្ថន័យដូចគ្នាដែរ បើយោងទៅបឹង Moeris ដែលស្ថិតនៅក្បែរនោះ។ នៅក្នុងយុគសម័យ Pharaonic, គេហៅទីក្រុងនោះថា Medinet el Fayum ដែលក្នុងនោះ shedet ជាតំបន់ក្រុងសំខាន់ជាងគេបំផុតនៃក្រុមប្រជាជន ដែលមានជំនឿខ្លាំងទៅលើ Sobek (ក្រពើមាស)។ ដោយហេតុនេះយោងតាមភាសាក្រិកគេហៅក្រុងនេះថា Crocodilopolish (ទីក្រុងក្រពើ) ទីក្រុងនេះបានគោរពបូជាសត្វក្រពើដ៏ពិសិដ្ឋមួយឈ្មោះថា Petsuchos ដែលត្រូវបានតុបតែងទៅដោយមាស និងបន្តោងត្បូង។ ក្រពើនោះគេដាក់ឱ្យរស់នៅក្នុងប្រាសាទទឹកត្រពាំងពិសេសមួយ និងផ្ដល់ចំណីដោយពួកអ្នកកាន់សាសនាដែលជាអាហារបានមកពីទស្សនា។ ពេលដែលក្រពើ Petsuchos ស្លាប់គេក៏យកក្រពើផ្សេងមួយទៀតមកជំនួសជាសក្ការៈ។

[១] បណ្ឌិត អ៊ុន សកក្កដា, *ទីតិនគរូបនីយវិទ្យា* (២០២០), ១១

Faiyum បានរកឃើញនៅអំឡុង ៤០០០ឆ្នាំមុនគ.ស ដែលជាទីក្រុងដែលចាស់ជាងគេបំផុតនៅក្នុងប្រទេសអេហ្ស៊ីប និងនៅតែបន្តជាទីក្រុងដ៏ចំណាស់ជាងគេនៅសកលលោក។[២]

### ១.១.១.៣. ការវិវត្តន៍នីក្រុងនៅកម្ពុជា

ស្ថានីយ៍ដែលបុរាណវិទូរកឃើញ និងជឿជាក់ថាជាការកកើតក្រុងដំបូងបង្អស់នៅកម្ពុជា គឺគុហាល្អាងស្ពាន ដែលជារូងភ្នំថ្មកំបោរមួយដែលស្ថិតនៅក្នុងភ្នំទាក់ទ្រាំង ភូមិគីឡូម៉ែត្រ៣៨ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ដែលមានចម្ងាយពីក្រុងបាត់ដំបងប្រមាណ ៤០គីឡូម៉ែត្រ ពីក្រុងបាត់ដំបងតាមបណ្តោយផ្លូវឆ្ពោះទៅខេត្តប៉ៃលិន។ គុហាល្អាងស្ពានត្រូវបានគេកាន់កាប់រស់នៅលើកដំបូងនៅមុន គ.ស ឆ្នាំ៧០០។ ស្ថានីយ៍មួយទៀតដែលមានភាពសំខាន់ដែរ នោះគឺស្ថានីយ៍សំរោងសែនដែលបានតាំងនៅប្រហែលមុន គ.ស ២៣០ ដល់ ៥០០។ ភស្តុតាងខាងវត្ថុបុរាណបង្ហាញថាតំបន់ទាំងនោះត្រូវបានគេហៅថាកម្ពុជានៅកំឡុងសហវត្សទីមួយ និងទីពីរមុន គ.ស ស្ថិតក្នុងវប្បធម៌ថ្មរំលីង ដែលប្រហែលជាបានរីកសាយភាយមកពីចិនភាគអាគ្នេយ៍មកកាន់ឧបទ្វីបឥណ្ឌូចិន។ នៅសតវត្សទីមួយនៃគ.ស ពួកអ្នកស្រុកបានអភិវឌ្ឍសង្គមឱ្យកាន់តែរឹងមាំ និងរៀបចំឱ្យមានទំនាក់ទំនងគ្នា។ ពួកក្រុមដែលរីកចំរើនជឿនលឿនបំផុតបានរស់នៅតាមបណ្តោយឆ្នេរ និងនៅតាមជ្រលងដងទន្លេមេគង្គក្រោម និងតំបន់ដីសណ្ត ដែលជាកន្លែងដែលពួកគេបានធ្វើការដាំដុះស្រូវ និងចិញ្ចឹមសត្វ។ ពួកគេបានស្លលោហៈរួមមាន ដែក និង សំរឹទ្ធ និងចេះជំនាញនាវាចរណ៍ច្បាស់លាស់ទៀតផង។ ស្ថានីយ៍ដែលបុរាណវិទូរកឃើញ និងជឿជាក់ថាជាការកកើតក្រុងដំបូងបង្អស់នៅកម្ពុជាគឺ គុហាល្អាងស្ពាន ដែលជារូងភ្នំថ្មកំបោរមួយដែលស្ថិតនៅក្នុងភ្នំទាក់ទ្រាំង ភូមិគីឡូម៉ែត្រ៣៨ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ដែលមានចម្ងាយពីក្រុងបាត់ដំបងប្រមាណ ៤០គីឡូម៉ែត្រពីក្រុងបាត់ដំបង តាមបណ្តោយផ្លូវឆ្ពោះទៅខេត្តប៉ៃលិន។ គុហាល្អាងស្ពានត្រូវបានគេកាន់កាប់រស់នៅលើកដំបូងនៅមុន គ.ស ឆ្នាំ៧០០។ ភស្តុតាងខាងវត្ថុបុរាណបង្ហាញថាតំបន់ទាំងនោះត្រូវបានគេហៅថាកម្ពុជានៅកំឡុងសហវត្សទីមួយ និងទីពីរមុន គ.ស ស្ថិតក្នុងវប្បធម៌ ថ្មរំលីង ដែលប្រហែលជាបានរីកសាយភាយមកពីចិនភាគអាគ្នេយ៍មកកាន់ឧបទ្វីបឥណ្ឌូចិន។ នៅសតវត្សទីមួយនៃគ.ស ពួកអ្នកស្រុកបានអភិវឌ្ឍសង្គមឱ្យកាន់តែរឹងមាំ និងរៀបចំឱ្យមានទំនាក់ទំនងគ្នា។ ពួកក្រុមដែលរីកចំរើនជឿនលឿនបំផុតបានរស់នៅតាមបណ្តោយឆ្នេរ និងនៅតាមជ្រលងដងទន្លេមេគង្គក្រោម និងតំបន់ដីសណ្តដែលជាកន្លែងដែលពួកគេបានធ្វើការដាំដុះស្រូវ និងចិញ្ចឹមសត្វ។ ពួកគេបានស្លលោហៈរួមមាន ដែក និង សំរឹទ្ធ និងចេះជំនាញនាវាចរណ៍ច្បាស់លាស់ទៀតផង។[៣]

[២] បណ្ឌិត អ៊ុន សកក្កដា, *នីតិនគរូបនីយវិទ្យា* (២០២០), ៣។

[៣] ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ* (ភ្នំពេញ, ១៩៧៣), ៥។

### ១.១.២. មូលហេតុនាំឱ្យមានការរៀបចំក្រុង

#### ១.១.២.១. កំណើនប្រជាជន

ជាទូទៅសមាសភាពនៃកំណើនប្រជាជនក្នុងទីក្រុងមានចំនួន ០៣សំខាន់ៗ៖ កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិ កំណើនដោយសារមានការចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋាននៃក្រុងថ្មី ដែលពីមុនមកតំបន់នេះជាទីជនបទប៉ុណ្ណោះ។ កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិបានធ្វើឱ្យមានការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន កំណើនប្រជាជន ចំណែកកំណើនដោយសារមានការចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋានដីនៃក្រុងថ្មីដែលពីមុនមកតំបន់នេះជាទីជនបទគ្រាន់តែជាធាតុចូលបន្ទាប់បន្សំប៉ុណ្ណោះ។[៤]

#### ១.១.២.២. ភាពក្រីក្រ

ការកំណត់អំពីស្ថានភាពក្រីក្រមានការលំបាកនៅក្នុងការកំណត់ណាស់តែជាទូទៅភាពក្រីក្រ សំដៅដល់ការដែលតម្រូវការរបស់មនុស្សមិនត្រូវបំពេញ។ ជារួមប្រទេសភាគច្រើនបានកំណត់ពីភាពក្រីក្រតាមរយៈប្រាក់ចំណូលទាបដែលពួកគេមិនអាចចាយវាយគ្រប់គ្រាន់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃឡើយ។ តម្រូវការរូបកាយ ចំណីអាហារ លំនៅដ្ឋាន ការងារ ធនធានទឹក អគ្គីសនី អនាម័យ សុខុមាលភាពសង្គមមានការខ្វះខាត។ លើសពីនេះសិទ្ធិសេរីភាពផ្នែកស្មារតីនិយាយជារួម និងនិយាយដោយឡែកសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោបាយក៏នៅមានកម្រិតដែរ។

ការសម្គាល់ពីភាពក្រីក្រត្រូវបានសង្កត់ធ្ងន់លើប្រាក់ចំណូលទាបរបស់បុគ្គលម្នាក់ៗ ពីព្រោះតែបញ្ហាផ្សេងៗដូចជា ចំនួននៃករណីឧក្រិដ្ឋកម្ម អំពើហិង្សា ឬអាយុសង្ឃឹមរស់ជាធម្មតាអ្នកដែលទទួលបានប្រាក់ចំណូលក្រោមកម្រិតមធ្យមត្រូវបានគេសន្មត់ថាជាជនក្រីក្រ។ យ៉ាងហោចណាស់ជាង ២០% នៃចំនួនប្រជាជនពិភពលោករស់នៅក្នុងបន្ទាត់នៃភាពក្រីក្រ ហើយ ៩០% ក្នុងចំនួននេះកំពុងស្ថិតក្នុងប្រទេសកំពុងអភិវឌ្ឍ។[៥]

#### ១.១.២.៣. កម្រិតជីវភាពរស់នៅ

ភាពខុសគ្នានៃស្ថានភាពភាពគឺជា កត្តាចម្បងដែលត្រូវបានគិតគូរនៅពេលមានការពិភាក្សាជុំវិញការជំរុញឱ្យមានការរៀបចំក្រុង។ កម្រិតជីវភាព និងប្រាក់បៀវត្សន៍ខ្ពស់នៅទីក្រុងជាកត្តាទាក់ទាញមនុស្សឱ្យមករស់នៅទីក្រុង។ ដរាបណាភាពខុសគ្នារវាងគ្នារវាងទីក្រុង និងជនបទមានគម្លាតខ្ពស់ប្រជាពលរដ្ឋនៅជនបទនៅតែចង់ចូលមករស់នៅក្នុងក្រុង។ ជាទូទៅកត្តាសេដ្ឋកិច្ច និងអាត្រានិកម្មភាពខ្ពស់ជាកត្តាជំរុញចំណាកស្រុក

[៤] បណ្ឌិត អ៊ុន សកក្កដា, *នីតិនគរូបនីយវិទ្យា* (២០២០), ៥។
[៥] បណ្ឌិត អ៊ុន សកក្កដា, *នីតិនគរូបនីយវិទ្យា* (២០២០), ៦។

ដោយសារតែពេលខ្លះការងារនៅជនបទនៅមានកម្រិត ដូច្នេះទោះជាទទួលបានប្រាក់ខែទាបក៏ត្រូវតែបង្ខំចិត្តចំណាកស្រុកដែរមកកាន់ទីក្រុងដែរ។ លើសពីនេះនៅទីក្រុងមានការប្រមូលផ្តុំដោយកត្តាសង្គម នយោបាយល្អប្រសើរខណៈពេលសេវាសុខាភិបាល និងអប់រំមានសម្បូរបែបរឹតរឹងតែធ្វើឱ្យអ្នករស់នៅមានអារម្មណ៍ថាមានសុវត្ថិភាពជាងកន្លែងណាៗទាំងអស់។[៦]

### ១.១.២.៤. ការដាក់សម្ពាធបរិស្ថាន

សម្ពាធដ៏ធំបំផុតរបស់ប្រជាពលរដ្ឋនៅជនបទពាក់ព័ន្ធវិស័យបរិស្ថានគឺ កង្វះដីបង្កបង្កើនផលដើម្បីធ្វើកសិកម្ម។ ករណីនេះកើតមានច្រើនក្នុងករណីដែលដីពួកគេទទួលបានដីពីដូនតា ឪពុកម្ដាយ របស់ខ្លួនត្រូវបានពួកគេចែកឱ្យកូនៗអស់។ ចំណែកផ្ទៃដីដែលនៅសល់មានទំហំតូចមិនសមល្មមសម្រាប់ធ្វើកសិកម្ម ឬបង្កបង្កើនផលដំណាំផ្សេងៗឡើយ ហើយពេលខ្លះស្ថានភាពដីនោះមានលក្ខណៈខ្សោះ និងគ្មានជីជាតិទៀត។ ប្រសិន បើក្រឡេកទៅមួយជ្រុងទៀត ចំពោះប្រជាពលរដ្ឋក្រីក្រនៅពេលដែលគាត់មានដីគ្រប់គ្រាន់ហើយ តែគាត់បែរជាកង្វះប្រព័ន្ធធារាសាស្រ្តស្រោចស្រព និងជីកសិកម្មសម្រាប់បង្កបង្កើនផលបានគ្រប់គ្រាន់វិញ។ ករណីនេះច្រើនកើតនៅក្នុងប្រទេសកំពុងអភិវឌ្ឍក្នុងតំបន់មេគង្គក្រោម។[7]

## ១.២. ការរៀបចំក្រុងឱ្យមានសោភ័ណ្ឌភាព និងសណ្ដាប់ធ្នាប់

ការរៀបចំក្រុងជាលក្ខណៈស្តង់ដាមួយត្រូវបានសង្កេតឃើញថាឈរលើគោលការណ៍សសរស្តម្ភចំនួន ០៥គឺ៖ ផលិតភាព និរន្តភាព ភាពដែលអាចរស់នៅបាន ភាពជាអ្នកដឹកនាំ និងការរចនាដ៏ល្អប្រសើរ។ ជារួមមានន័យថាត្រូវធ្វើយ៉ាងណាបង្កើតកន្លែងមួយដែលមានផលិតភាព និងនិរន្តរភាព និងភាពអាចរស់នៅបានតាមរយៈភាពជាអ្នកដឹកនាំ និងការរួមបញ្ចូលគ្នានៃការរចនាក្រុងមួយដ៏ល្អប្រសើរ។

### ១.២.១. សោភ័ណ្ឌភាព

#### ១.២.១.១. ពេលថ្ងៃ

##### ក. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ

រាល់ការរៀបចំកសាងសំណង់ដូចជា សំណង់រោងចក្រ សហគ្រាស ស្ថានីយប្រេង ឃ្លាំងទំនិញ និងសំណង់បុរី លំនៅដ្ឋាន ផ្ទះល្វែង ផ្សារ មន្ទីរពេទ្យ សាលារៀន ជាដើម ត្រូវតែធ្វើឡើងដោយគោរពតាមស្តង់ដារដែលច្បាប់បានកំណត់។ ចំពោះការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវត្រូវអនុលោមតាមច្បាប់ផ្លូវថ្នល់មាត្រា៣០ ចែងថា

[៦] បណ្ឌិត អ៊ុន សកក្កដា, *នីតិនគរូបនីយវិទ្យា* (២០២០), ៦។

[៧] បណ្ឌិត អ៊ុន សកក្កដា, *នីតិនគរូបនីយវិទ្យា* (២០២០), ៧។

ដើម្បីធានាដល់ការធ្វើចរាចរណ៍លើផ្លូវល្បឿនលឿន ផ្លូវជាតិ ផ្លូវខេត្ត ប្រកបដោយសុវត្ថិភាពរាល់សំណង់ដែលមានច្រកចេញចូលជាផ្លូវថ្នល់ខាងលើនេះត្រូវអនុវត្តដូចខាងក្រោម៖

- ការសាងសង់សំណង់ដូចជា ស្ថានីយប្រេងឥន្ធនៈ ស្ថានីយហ្គាស កន្លែងលាងយានយន្តយានដ្ឋាន ឬសំណង់ប្រហាក់ប្រហែលផ្សេងៗទៀត ដែលមានមនុស្សជួបជុំគ្នាមធ្យមត្រូវស្ថិតក្នុងចម្ងាយយ៉ាងតិច ១៥ម៉ែត្រ ពីខ្សែបន្ទាត់ព្រំដីចំណីផ្លូវ
- ការកសាងសង់មជ្ឈមណ្ឌលពាណិជ្ជកម្ម ពហុកីឡាដ្ឋាន ទីលានប្រកួត រោងមហោស្រព មន្ទីរពេទ្យ គ្រឹះស្ថានសិក្សា ការរៀបចំផ្សារ ផ្សារណាត់ ពិព័រណ៍ទំនិញ ឬកិច្ចការផ្សេងទៀតដែលមានមនុស្សជួបជុំគ្នាច្រើន ត្រូវស្ថិតក្នុងចម្ងាយយ៉ាងតិចបំផុត ៥០ម៉ែត្រ ពីខ្សែបន្ទាត់ព្រំដីចំណីផ្លូវថ្នល់
- ការកំណត់ដូចមានចែងក្នុងចំណុចទី១ និងទី២ ខាងលើនេះ មិនអនុវត្តចំពោះរាល់សំណង់ដែលបានសាងសង់មុនស្របតាមបទប្បញ្ញត្តិជាធរមានឡើយ
- ការកំណត់ចម្ងាយដូចមានចែងនៅចំណុចទី១ និងទី២ ខាងលើ ចំពោះផ្លូវជនបទត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។[៤]

បន្ថែមពីនេះទៀតអាជ្ញាធរពាក់ព័ន្ធជួយពង្រឹងការផ្សព្វផ្សាយដល់មន្ត្រីជំនាញក្រោមឱវាទ និងរឹតបន្តឹងការអនុញ្ញាតច្បាប់សាងសង់ការត្រួតពិនិត្យនូវលក្ខខណ្ឌបច្ចេកទេសពាក់ព័ន្ធមុននឹងផ្តល់អាជ្ញាប័ណ្ណ និងការចុះត្រួតពិនិត្យទប់ស្កាត់ និងឱ្យរុះរើរាល់គម្រោងសាងសង់ណាដែលពុំបានគោរពទៅតាមបញ្ញត្តិនៃច្បាប់។

ដើម្បីអាចរៀបចំហេដ្ឋារចនាសម្ព័ន្ធឱ្យកាន់តែមានសណ្តាប់ធ្នាប់ លុះត្រាតែក្រុងនោះគោរពតាមប្លង់គោល និងប្រើប្រាស់ដីធ្លីនៃក្រុងនីមួយៗ។ ប្លង់គោល គឺមានសារៈសំខាន់ជាខ្លាំងចំពោះនយោបាយនគរូបនីយកម្ម ឬអាចនិយាយបានថាជាឯកសារដែលមិនអាចខ្វះបានក្នុងនយោបាយនគរូបនីយកម្មក៏ដូចជាការអភិវឌ្ឍប្រទេស។ លើសពីនេះទៅទៀត ប្លង់គោលនេះវាជាច្បាប់មួយដែលបានកំណត់រាល់ការសាងសង់សំណង់ទាំងអស់ត្រូវតែគោរពតាមប្លង់នេះជាដាច់ខាត ហើយមិនអាចមានអគារ ឬសំណង់ណាមួយសាងសង់ដោយបំពានប្លង់នេះបានឡើយ បើមិនដូចនោះនឹងត្រូវទទួលរងនូវទណ្ឌកម្មនានាជាក់ជាមិនខាន។ ចំពោះប្លង់គោលនេះអាចលេចឡើងតាមរយៈ ០២រូបភាពគឺ៖

- **ប្លង់គោលសម្រាប់ខេត្ត ឬក្រុង ៖** ត្រូវរៀបចំដោយគណៈកម្មាធិការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ឬអនុគណៈកម្មាធិការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ តាមបណ្តាលខេត្ត-ក្រុង ហើយប្លង់

[៤] ច្បាប់ស្តីពីផ្លូវថ្នល់, គ្មានលេខ, ១១ មេសា ២០១៤, មាត្រា៣០។

គោលនេះត្រូវតែមានការយល់ព្រមពីគណៈកម្មាធិការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

- **ប្លង់គោលសម្រាប់តំបន់ពិសេស ៖** ត្រូវបានបង្កើតឡើង ដើម្បីការពារនូវបេតិកភណ្ឌ បរិស្ថាន និងដើម្បីធានាអភិវឌ្ឍសេដ្ឋកិច្ច។ ចំពោះតំបន់ពិសេសណាមួយដែលគណៈរដ្ឋមន្ត្រីបានកំណត់គណៈកម្មាធិការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ មានភារកិច្ចរៀបចំប្លង់គោលនេះសម្រាប់ដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត។

រីឯប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ ត្រូវបានបង្កើតឡើងដោយផ្អែកទៅលើប្លង់គោលដោយប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ គឺជាកាតាលីករជម្រុញភាពខ្វះចន្លោះនៃការអនុវត្តប្លង់គោល។ បើចង់រៀបចំឱ្យមានជាប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ លុះត្រាតែមានប្លង់គោលសិន ព្រោះប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ គឺអនុលោមទៅតាមប្លង់គោលដោយសំដៅជ្រៀកបន្ថែមតំបន់នីមួយៗដែលបានកំណត់នៅក្នុងប្លង់គោល។

សមត្ថកិច្ចក្នុងការរៀបចំប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ ត្រូវបានប្រគល់ឱ្យទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់រាជធានី ខេត្ត។ មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់រាជធានី ខេត្ត ធ្វើការស្រាវជ្រាវទៅលើតំបន់នីមួយៗ ក្នុងរាជធានី ខេត្ត ដែលខ្លួនមានសមត្ថកិច្ចដើម្បីស្វែងយល់ពីសក្ដានុពលនៃតំបន់ទាំងនោះ ហើយរៀបចំប្លង់ប្រើប្រាស់ ដីធ្លី និងសំណង់ ដោយធ្វើយ៉ាងណាឱ្យបានសមស្របទៅនឹងសក្ដានុពលរបស់ដីនៃតំបន់នីមួយៗ ក៏ដូចជាឱ្យសមស្របទៅនឹងប្លង់គោល។ ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ ដែលរៀបចំដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់នោះ ត្រូវមានការយល់ព្រមពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងត្រូវមានការគោរពពីសំណាក់ឯកជន និងអាជ្ញាធរសាធារណៈផងដែរ។[៩]

### ខ. ការរៀបចំចរាចរណ៍

ចរាចរណ៍ជាកត្តាសំខាន់មួយក្នុងការធ្វើឱ្យទីក្រុងមានសោភ័ណ្ឌភាពបានល្អ លុះត្រាតែអាជ្ញាធរពាក់ព័ន្ធយកចិត្តទុកដាក់ធ្វើយ៉ាងណាកុំឱ្យមានការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍ ហើយបញ្ហានេះជាកង្វល់មួយដែលអាជ្ញាធរមូលដ្ឋានតែងតែរិះរកមធ្យោបាយ ដើម្បីធ្វើយ៉ាងណាកាត់បន្ថយបញ្ហានេះឱ្យខានតែបានតាមរយៈការចុះអប់រំប្រជាពលរដ្ឋនៅតាមមូលដ្ឋានឱ្យយល់កាន់តែច្បាស់ អំពីមូលហេតុដែលនាំឱ្យមានគ្រោះថ្នាក់ចរាចរណ៍ និងការកកស្ទះចរាចរណ៍ ព្រមទាំងស្វែងរកដំណោះស្រាយដូចខាងក្រោម៖

- **កត្តាមនុស្ស** ៖ កត្តាមនុស្សត្រូវគេឃើញថាមានច្រើនជាងគេ ដោយសារតែការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត និងភាពធ្វេសប្រហែសរបស់ប្រជាពលរដ្ឋនៅមានចំនួនច្រើននៅឡើយ។ ដូច្នេះត្រូវតែមានវិធានការព្រមទាំងសហការជាមួយអង្គភាពពាក់ព័ន្ធនានា ដើម្បីធ្វើការចុះទៅបណ្ដុះបណ្ដាល និងណែនាំ

[៩] បណ្ឌិត អ៊ុន សកក្កដា, *នីតិនគរូបនីយវិទ្យា* (២០២០), ១៥៤ ១៥៥។

ដល់ប្រជាពលរដ្ឋនៅមូលដ្ឋានឱ្យបានយល់ដឹងពីច្បាប់ចរាចរណ៍ តាមរយៈការពន្យល់តាមបណ្ដាញសង្គម ការបំផុសការអប់រំតាមគ្រឹះស្ថានសិក្សាគ្រប់កម្រិតឱ្យបានយល់ច្បាស់ពីរបៀបនៃចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ ស្លាកសញ្ញាចរាចរណ៍ គំនូសសញ្ញាចរាចរណ៍ និងសីលធម៌ក្នុងពេលបើកបរ។

- **កត្តាផ្លូវ** ៖ ផ្លូវគឺជាផ្នែកមួយដែលសំខាន់មួយចូលរួមចំណែកក្នុងការបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍ និងការកកស្ទះចរាចរណ៍។ ដើម្បីឱ្យបញ្ហានេះអាចដោះស្រាយបាន អាជ្ញាធរពាក់ព័ន្ធត្រូវអនុវត្តដូចខាងក្រោម៖
  - ត្រូវយកមកវិញនូវចិញ្ចើមផ្លូវ និងរក្សាចិញ្ចើមផ្លូវឱ្យបានសម្រាប់ទុកអ្នកថ្មើរជើងធ្វើដំណើរ
  - ត្រូវមានរនាំងសុវត្ថិភាពនៅតាមចិញ្ចើមផ្លូវ ដើម្បីការពារសុវត្ថិភាពអ្នកថ្មើរជើង
  - ត្រូវសាងស្ពានអាកាសសម្រាប់អ្នកថ្មើរជើងឆ្លងកាត់ ដោយត្រូវសាងសង់នៅតំបន់ដូចជា៖ (មន្ទីរពេទ្យ ផ្សារ រោងចក្រ សាលារៀន និងតំបន់ដែលជាទីប្រជុំជនមានមនុស្សឆ្លងកាត់ជាប្រចាំ)
  - មិនត្រូវអនុញ្ញាតឱ្យមានការលក់ដូរ ឬប្រកបអាជីវកម្មផ្សេងៗ នៅលើចិញ្ចើមផ្លូវ
  - ហាមចតយានជំនិះគ្រប់ប្រភេទនៅលើផ្លូវសាធារណៈដែលបំពាននឹងច្បាប់ចរាចរណ៍ផ្លូវគោក
  - ត្រូវជួសជុលផ្លូវណាដែលខូចខាតទោះមានការខូចតិច ឬច្រើនក៏ដោយត្រូវដាក់ស្លាកសញ្ញាសម្គាល់ និងភ្លើងសម្គាល់កន្លែងជួសជុលនោះជាដើម។
- **កត្តាយានជំនិះ** ៖ យានជំនិះគឺជាកត្តាចម្បងមួយដែរ ក្នុងការចូលរួមបង្កគ្រោះថ្នាក់ចរាចរណ៍។ បញ្ហានេះបណ្ដាលមកពីប្រជាពលរដ្ឋមួយចំនួននៅប្រើប្រាស់យានជំនិះចាស់ៗ ឬជួសជុលច្រើន ហើយយានជំនិះទាំងនោះមានពេលខ្លះកំពុងតែធ្វើដំណើរនៅលើផ្លូវស្រាប់តែមានបញ្ហាខូចត្រង់ចំណុចណាមួយជាយថាហេតុដែលជាហេតុអាចបណ្ដាលឱ្យមានគ្រោះថ្នាក់ចរាចរណ៍បានក្នុងអំឡុងធ្វើដំណើរ។ ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះក្រសួងសាធារណការ និងដឹកជញ្ជូន បានចាត់វិធានការឱ្យមន្ទីរសាធារណការ និងដឹកជញ្ជូន ទូទាំងរាជធានី ខេត្ត ឱ្យប្រជាពលរដ្ឋដែលជាម្ចាស់កម្មសិទ្ធិយានយន្តទាំងអស់ត្រូវតែទៅពិនិត្យបច្ចេកទេសយានជំនះរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងទៀងទាត់ ទៅតាមសេចក្ដីប្រកាសរបស់ក្រសួង។

### គ. ការរៀបចំឱ្យមានចិញ្ចើមផ្លូវ

ដើម្បីរៀបចំចិញ្ចើមផ្លូវឱ្យបានល្អ ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានគួរ៖

- ណែនាំ និងអនុវត្តឱ្យបានតឹងរឹងចំពោះអ្នកដែលបានយកចិញ្ចើមផ្លូវមកប្រើប្រាស់ជាកម្មសិទ្ធិផ្ដាច់មុខ ដូចជាដាក់រនាំងយកធ្វើជាកន្លែងអាជីវកម្មលក់ដូរ ឬផ្ញើយានជំនិះផ្សេងៗ
- ណែនាំដល់ម្ចាស់ក្រុមហ៊ុននានា មិនត្រូវយកស្លាកយីហោរបស់ខ្លួនទៅដាក់តាំងនៅលើចិញ្ចើមផ្លូវសាធារណៈឡើយ

- ហាមចតយានជំនិះគ្រប់ប្រភេទនៅលើផ្លូវសាធារណៈដែលបំពាននឹងច្បាប់ចរាចរណ៍ផ្លូវគោក
- ហាមមិនឱ្យមានការសាងសង់សំណង់ផ្សេងៗ ដែលរំលោភលើចិញ្ចើមផ្លូវ
- ហាមឃាត់ការកាប់គាស់ និងជួសជុលចិញ្ចើមផ្លូវគ្មានសណ្តាប់ធ្នាប់
- ហាមឃាត់ការដាំដើមឈើគ្មានសណ្តាប់ធ្នាប់
- ការសាងសង់ចិញ្ចើមផ្លូវទាបខ្ពស់ៗ ដែលបង្កការលំបាកដល់អ្នកធ្វើដំណើរ។ល។

**១.១.១.២. ពេលយប់**

សោភ័ណភាពនាពេលយប់ជាកត្តាមួយដែលទាក់ទាញយ៉ាងសំខាន់ ដែលអាជ្ញាធរពាក់ព័ន្ធត្រូវយកចិត្តទុកដាក់។ ដើម្បីទាក់ទាញប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងភ្ញៀវទេសចរណ៍ដែលធ្វើដំណើរឆ្លងកាត់ និងមកលេងកំសាន្តនៅក្នុងទីក្រុងនាពេលរាត្រី អាជ្ញាធរត្រូវរៀបចំការតុបតែង លម្អ និងបំពាក់ភ្លើងបំភ្លឺនៅតាមទីតាំងមួយចំនួនដូចខាងក្រោម៖

- នៅតាមបណ្តាកន្លែងកំសាន្តនានា ដូចជា សួនច្បារ កន្លែងហាត់ប្រាណ ជាដើម
- ផ្លូវ ស្ពាន ជុំវិញក្រុង
- សំណង់អគាររបស់ស្ថាប័ន អង្គភាពសាធារណៈ និងគ្រឹះស្ថានសិក្សាទាំងរដ្ឋ និងឯកជន នៅក្នុងក្រុង

**១.២.២. សណ្តាប់ធ្នាប់**

នាពេលបច្ចុប្បន្ននេះ ការរៀបចំសន្តិសុខសណ្តាប់ធ្នាប់ក្នុងទីក្រុងត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំងតាមរយៈការខិតខំប្រឹងប្រែងធ្វើយ៉ាងណារក្សាឱ្យបាននូវសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋទាំងនៅមូលដ្ឋានក្រុងផ្ទាល់ និងភ្ញៀវទេសចរណ៍ដែលអញ្ជើញមកទស្សនាបានយ៉ាងល្អប្រសើរផងដែរ។ ទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងនេះក្តីក៏បញ្ហា សន្តិសុខ សណ្តាប់ធ្នាប់ក៏នៅតែមានបញ្ហាចោទមួយចំនួនផងដែរដោយសារតែការយល់ដឹងរបស់ប្រជាពលរដ្ឋមួយចំនួននៅមានកម្រិតដែលទាក់ទងទៅនឹងច្បាប់ និងបទប្បញ្ញត្តិមួយចំនួនទៀតដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីផ្លូវថ្នល់ ផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ ឃុំមានសុវត្ថិភាព" ច្បាប់ និងបទដ្ឋានគតិយុត្តដែលអនុវត្តក្នុងវិស័យនគរូបនីយកម្ម និងសំណង់ជាដើម។ ទោះបីជាយ៉ាងនេះក្តីក៏អាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់នៅតែព្យាយាមរិះរកដំណោះស្រាយឱ្យទាន់សភាពការណ៍ និងដោយសន្តិវិធី ដើម្បីធ្វើយ៉ាងណាកាត់បន្ថយបញ្ហាទាំងអស់នោះបន្តិចម្តងៗ សំដៅធ្វើយ៉ាងណាប្រែក្លាយទីក្រុងនៅកម្ពុជាក្លាយជាទីក្រុងគំរូមួយដែលមានសណ្តាប់ធ្នាប់ល្អប្រសើរឡើងបន្ថែមទៀត។

### ១.២.២.១. សន្តិសុខ

#### ក. សុវត្ថិភាពបុគ្គល

ប្រជាពលរដ្ឋគ្រប់ៗរូបតែងតែចង់បាននូវសុវត្ថិភាពផ្ទាល់ខ្លួន។ ដើម្បីធានា និងការពារដល់សន្តិសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋបានអាជ្ញាធរពាក់ព័ន្ធត្រូវរៀបចំដូចខាងក្រោម៖

- **ចរាចរណ៍** ៖ អត្រាគ្រោះថ្នាក់ចរាចរណ៍នាពេលបច្ចុប្បន្ននេះមានកើនឡើងជាលំដាប់ពីមួយថ្ងៃទៅមួយថ្ងៃ។ ដើម្បីកាត់បន្ថយបញ្ហានេះអាជ្ញាធរពាក់ព័ន្ធត្រូវណែនាំដល់ប្រជាពលរដ្ឋត្រូវ៖
  - គោរពភ្លើងសញ្ញាចរាចរណ៍ គំនូសសញ្ញាចរាចរណ៍ និងស្លាកសញ្ញាចរាចរណ៍ឱ្យបានត្រឹមត្រូវ
  - កុំបើកបរបញ្ច្រាសផ្លូវ
  - កុំបើកបរលើផ្លូវអាទិភាពរបស់អ្នកដទៃ
  - ហាមចតយានជំនះគ្រប់ប្រភេទនៅលើផ្លូវសាធារណៈ ដែលបំពាននឹងច្បាប់ចរាចរណ៍ផ្លូវគោក
  - ត្រូវចេះគោរព និងអធ្យាស្រ័យគ្នាទៅវិញទៅមក
  - ហាមលក់ដូរលើចិញ្ចើមផ្លូវ
  - គួរប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ
  - មានសីលធម៌ក្នុងពេលបើកបរជាដើម។
- **ដើរហើរ** ៖ ប្រជាពលរដ្ឋគ្រប់ៗរូបតែងតែមានក្តីបារម្ភចំពោះបញ្ហាសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួន ដោយសារតែមានបញ្ហាមួយចំនួនដូចជា ចោរកម្ម ឆក់ ប្លន់ បាញ់បោះ ក្មេងទំនើង។ល។ ដើម្បីចូលរួមកាត់បន្ថយបញ្ហានេះ អាជ្ញាធរពាក់ព័ន្ធត្រូវតែអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលនយោបាយ "ភូមិ ឃុំ មានសុវត្ថិភាព" ទាំង ០៩ចំណុច ជាពិសេសគឺត្រូវធ្វើយ៉ាងណាកាត់បន្ថយឱ្យបាននូវសកម្មភាពមួយចំនួនដូចខាងក្រោម៖
  - គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ
  - គ្មានក្មេងទំនើង
  - គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ ជាដើម។[10]

#### ខ. សម្ភារៈ

[10] ផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ ឃុំមានសុវត្ថិភាព", លេខ០២២ផក, ១០ សីហា ២០១២, ២ (ចាប់ពីពេលនេះតទៅហៅថាផែនការណែនាំលេខ០២២ផក)។

សុវត្ថិភាពខាងផ្នែកសម្ភារៈក៏ជាផ្នែកមួយ ដែលត្រូវការអាជ្ញាធរពាក់ព័ន្ធយកចិត្តទុកដាក់ផងដែរ ព្រោះប្រសិនបើប្រជាពលរដ្ឋបាត់បង់សម្ភារៈច្រើនវាអាចនឹងបង្កជាក្តីកង្វល់ដល់ពួកគាត់ ហើយអំពើនេះអាចបង្កជាអសន្តិសុខដល់សង្គមផងដែរ។ កត្តាដែលនាំឱ្យមានសុវត្ថិភាពខាងផ្នែកសម្ភារៈលុះត្រាតែក្នុងមូលដ្ឋាននោះ៖

- គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ
- គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់
- គ្មានក្មេងទំនើង
- គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ ជាដើម។

**គ.ចំណីអាហារ**

ការត្រួតពិនិត្យចំណីអាហារ គឺជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណអាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) នៃក្រសួងពាណិជ្ជកម្មដែលមានសាខាកាំកុងត្រូលរាជធានី-ខេត្តជាសេនាធិការ។ សាខាកាំកុងត្រូលរាជធានី-ខេត្តមានភារកិច្ចដូចខាងក្រោម៖

- ផ្តល់សេវាត្រួតពិនិត្យទំនិញនាំចេញ-នាំចូលរួមជាមួយស្ថាប័នគយ និងរដ្ឋាករផ្អែកលើកិច្ចសម្របសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- ធ្វើវិញ្ញាបនបត្រចំពោះទំនិញនាំចេញតាមសំណើរបស់អ្នកស្នើសុំ ដើម្បីបំពេញលក្ខខណ្ឌតម្រូវនៃប្រទេសនាំចូល
- ត្រួតពិនិត្យភាពអនុលោមតាមស្តង់ដារជាតិនូវគុណភាព សុវត្ថិភាពផលិតផលទំនិញ ដែលមានប្រើសញ្ញាស្តង់ដារជាតិ
- សហការត្រួតពិនិត្យជាមុននូវប្រតិវេទន៍នៃផលិតទំនិញ ឬសេវាទាំងឡាយណា ដែលអាចប៉ះពាល់ដល់សុវត្ថិភាព សុខភាពនៃអ្នកប្រើប្រាស់ ឬផលិតកម្ម ឬពាណិជ្ជកម្ម នៃផលិតផលទំនិញ និងសេវាកម្មទាំងនោះដែលផ្តល់ដោយស្ថាប័នមានសមត្ថកិច្ច
- ត្រួតពិនិត្យទំនិញផលិតផលទំនិញ និងសេវា ក្នុងដំណាក់កាលធ្វើចរាចរណ៍ពាណិជ្ជកម្មលើទីផ្សារតាំងពិព័រណ៍ បង្ក្រាបការក្លែងបន្លំ និងប្រមូលកម្រៃសេវាត្រួតពិនិត្យទំនិញនាំចេញ-នាំចូល ដែលកំណត់ដោយប្រកាសរួមរបស់ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកដ្ឋានប្រគល់ឱ្យ។”[១១]

[១១] ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សាខាកាំកុងត្រូលរាជធានី-ខេត្ត, លេខ២៣៣ព.ណបល.ប្រក, ១៤ កក្កដា ២០១៦, ប្រការ១។

**១.២.២.២. ភាពស្ងប់ស្ងៀម**

ដើម្បីឱ្យជីវិតរស់នៅបានក្តីសុខ មនុស្សភាគច្រើនតែងតែត្រូវការភាពស្ងប់ស្ងៀម។ ដូចនេះអាជ្ញាធរពាក់ព័ន្ធមុននឹងរៀបចំប្លង់គោលនៃការអភិវឌ្ឍក្រុងត្រូវគិតលើបញ្ហានេះ ដោយត្រូវបែងចែកទីតាំងដែលអាចបង្កជាការរំខានដោយសំឡេងខ្លាំងៗ ដូចជា កន្លែងកំសាន្ត ក្លឹប បារ ខារ៉ាអូខេ ភោជនីយដ្ឋាននានា ឱ្យនៅឆ្ងាយក្រុង និងណែនាំដល់ម្ចាស់ទីតាំងទាំងនោះឱ្យចេះរៀបចំប្រព័ន្ធកាត់បន្ថយសំឡេងឱ្យត្រូវតាមស្តង់ដារ និងបច្ចេកទេស។ ម្យ៉ាងវិញទៀត អាជ្ញាធរមូលដ្ឋានត្រូវតែចុះត្រួតពិនិត្យជាប្រចាំនូវរាល់កន្លែងកំសាន្ត ក្លឹប បារ ខារ៉ាអូខេ ភោជនីយដ្ឋាននានា ដែលមាននៅក្នុងក្រុងជៀសវាងមានការបង្កការរំខានដោយសំឡេងណាមួយ ព្រមទាំងត្រូវណែនាំដល់ប្រជាពលរដ្ឋដែលមានកម្មវិធីនានា ដូចជា ពិធីរៀបអាពាហ៍ពិពាហ៍ ខួប កំណើត ជប់លៀងជាដើម ដោយមិនត្រូវមានការច្រៀងរាំដល់យប់ជ្រៅពេកនោះទេ ព្រោះវាអាចបង្កជាការរំខានដល់ប្រជាពលរដ្ឋដែលនៅជិតតំបន់នោះផងដែរ។

**១.២.២.៣. អនាម័យ**

នាពេលបច្ចុប្បន្ន បញ្ហាបរិស្ថាននៅតែចោទជាបញ្ហានៅឡើយដោយក្នុងនោះវាបានបង្កជាបញ្ហានានាដែលបានផ្តល់ផលប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ និងរុក្ខជាតិយ៉ាងធ្ងន់ធ្ងរដែលទាមទារឱ្យមានការបង្កើតការយកចិត្តទុកដាក់ និងរៀបចំវាឡើងវិញ ដើម្បីធ្វើយ៉ាងណាដោះស្រាយបញ្ហានេះឱ្យបានល្អប្រសើរ។

**១.២.៣. ទីក្រុងគ្មានការបំពុលទាំង៥**

**១.២.៣.១. គ្មានការបំពុលទឹក**

ទឹកមានសារៈសំខាន់ណាស់សម្រាប់ទ្រទ្រង់ជីវិតមនុស្ស សត្វ និងរុក្ខជាតិ។ ប៉ុន្តែការលេចចេញនូវឥទ្ធិពលអវិជ្ជមានទៅលើគុណភាពបរិស្ថាននៅក្នុងទឹកបានបង្កឱ្យមានផលវិបាកដល់មនុស្ស សត្វ ដោយសារការប៉ះពាល់សារធាតុគីមីរាប់ម៉ឺនប្រភេទរួមទាំងកាកសំណល់ដែលផ្ទុកជាតិពុលផ្សេងៗជាច្រើន តាមរយៈការបោះកាកសំណល់លាមក ឬសំរាមទៅតាមប្រព័ន្ធលូទឹក និងតាមរូបភាពផ្សេងៗទៀត ជាហេតុបង្កឱ្យបរិស្ថានទឹកត្រូវបានបំពុល។

ទឹកកខ្វក់ សំដៅដល់ទឹកដែលបានប្រែប្រួលចរិតលក្ខណៈដើមរបស់វាក្រោយពីការប្រើប្រាស់រួមមានដូចជាទឹកសំណល់ពីផ្ទះបាយ បន្ទប់ទឹក ការបោកគក់ ឬការលាងសម្អាតនានា និងទឹកសំណល់ពីបង្គន់អនាម័យរួមទាំងទឹកនោម និងលាមក ដែលបញ្ចេញពីលំនៅដ្ឋាន បុរីលំនៅដ្ឋាន ទីក្រុងរណប អគារអាជីវកម្ម អគារពាណិជ្ជកម្ម

សេវាកម្ម និងតំបន់រមណីយដ្ឋាន ឬមជ្ឈមណ្ឌលកំសាន្ត។[១២] ការបំពុលបរិស្ថានទឹកអាចជះឥទ្ធិពលអាក្រក់ដល់សោភ័ណភាពបរិស្ថានអាស្រ័យទៅតាមកម្រិតនៃការបំពុល ដែលភាគច្រើនមាននៅតាមទីកន្លែងសំខាន់ៗមួយចំនួនដូចជា រមណីយដ្ឋាន ទីក្រុង ទីប្រជុំជន ភូមិ ទីកំសាន្ត ទីសាធារណៈជាដើម។ ប្រភេទនៃការបំពុលទឹកកើតឡើងតាមរយៈកត្តាមួយចំនួន ដូចខាងក្រោម៖

- **កត្តាមនុស្ស** ៖ ទាក់ទងទៅនឹងមុខរបរអាជីវកម្មដែលប្រជាពលរដ្ឋប្រកបមុខរបរៀងរាល់ថ្ងៃ ដូចជា វិស័យឧស្សាហកម្ម វិស័យពាណិជ្ជកម្ម វិស័យសេវាកម្ម វិស័យកសិកម្ម ជាដើម ការប្រើប្រាស់ជីគីមីហួសកម្រិត និងមិនបានគ្រប់គ្រងឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដែលនាំឱ្យហូរធ្លាក់ចូលទៅក្នុងប្រភពទឹកដែលអាចបណ្តាលឱ្យបំពុលទឹក។ ការធ្វើដំណើរកំសាន្តនៅតាមទូក កប៉ាល់ ឬកាណូតអ្នកដំណើរខ្លះមិនបានរៀបចំទុកដាក់សំរាមឱ្យបានត្រឹមត្រូវ ដែលជាហេតុធ្វើឱ្យកាកសំណល់ទាំងអស់នោះធ្លាក់ចូលទៅក្នុងទឹក។ បន្ថែមពីនេះទៀត ការបន្ទោបង់គ្មានសណ្តាប់ធ្នាប់ ក៏ជាផ្នែកមួយដែលបណ្តាលឱ្យមានការបំពុលទឹកបានផងដែរ។
- **កត្តាធម្មជាតិ** ៖ សារធាតុនីត្រូសែនមាននៅក្នុងទឹកភ្លៀង ហើយនៅពេលដែលទឹកភ្លៀងធ្លាក់ចូលទឹកស្ទឹង ស្រះ ឬទន្លេ ក៏បានបំប្លែងទៅជាអាស៊ីតនីត្រាតដែលបង្កគ្រោះថ្នាក់ និងបំផ្លាញដល់ជីវិតរុក្ខជាតិ។

### ១.២.៣.២. គ្រោះការបំពុលខ្យល់

ការបំពុលខ្យល់ គឺជាបញ្ហាមួយដែលបានកើតមានឡើងនៅក្នុងសម័យទំនើបនេះដោយសារតែការអភិវឌ្ឍយ៉ាងឆាប់រហ័សក្នុងតំបន់ជាច្រើន ដូចជា ឧស្សាហកម្ម ការដឹកជញ្ជូន វិស័យកសិកម្ម លំនៅដ្ឋាន រោងចក្រផលិតថាមពលកម្តៅ ការប្រើប្រាស់ប្រេងឥន្ធនៈសម្រាប់ផលិតថាមពលឧស្សាហកម្ម និងការប្រើប្រាស់ប្រេងឥន្ធនៈជីវម៉ាសគឺជាកត្តាធំៗ ដែលរួមចំណែកនាំឱ្យមានការបំពុលខ្យល់។

ការបំពុលខ្យល់ កើតឡើងដោយសារធាតុគីមី ឬជីវៈសេរីរាង្គដែលបំផ្លាញ ឬបណ្តាលឱ្យមានផលប៉ះពាល់ដល់មនុស្ស ឬភាវៈមានជីវិតទាំងឡាយ និងបំផ្លាញដល់បរិស្ថានក្នុងបរិយាកាស។ បរិយាកាសគឺជាប្រព័ន្ធធម្មជាតិយ៉ាងរឹងមាំដែលទ្រទ្រង់រាល់ជីវិតមនុស្ស សត្វនានានៅលើផែនដី។ ការបំផ្លាញស្រទាប់អូហ្សូន គឺជាការបំផ្លាញរនាំងការពារផែនដីពីកាំរស្មីអ៊ុលត្រាវីយ៉ូលេដែលបង្កផលវិបាកដល់ជីវិតលើផែនដី។ ការបំពុលខ្យល់បានកំពុងជះឥទ្ធិពលជាអវិជ្ជមានជាច្រើនមកលើសុខភាពមនុស្ស សត្វ និងរុក្ខជាតិ ហើយពពួកសត្វ និងរុក្ខជាតិមួយចំនួនបានទទួលនូវការគំរាមកំហែង និងមួយចំនួនទៀតអាចឈានដល់ការផុតពូជ។ ម្យ៉ាងទៀតការសាយ

[១២] អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់, លេខ២៣៥អនក្រ.បក ២៥ ធ្នូ ២០១៧, មាត្រា៤ កថាខណ្ឌទី១ (ចាប់ពីពេលនេះតទៅហៅថាអនុក្រឹត្យលេខ២៣៥អនក្រ.បក)។

ភាយនៃសារធាតុគីមីងាយធ្វើឱ្យមនុស្សចាស់ និងកុមាររងគ្រោះកើតជំងឺដែលបណ្តាលមកពីការបំពុល ហើយចំណែកឯអ្នកមានជំងឺបញ្ហាសួត ឬបេះដូងស្រាប់នោះអាចបណ្តាលឱ្យសុខភាពកាន់តែធ្ងន់ធ្ងរទៅៗ ដោយសារតែការបំពុលខ្យល់នេះ។ មិនតែប៉ុណ្ណោះ ក៏មានជំងឺមួយចំនួនទៀតដែលបង្កឡើយដោយការបំពុលខ្យល់តែមិនមានបង្ហាញរោគសញ្ញា ជំងឺទាំងនោះមានដូចជា រលាកទងសួតរ៉ាំរ៉ៃ រាគ ហឺត មហារីក ជាដើម ដែលបណ្តាលមកពីការស្រូបយកខ្យល់ដែលបានបំពុលនោះ។ មូលហេតុនៃការបំពុលខ្យល់មានដូចខាងក្រោម៖

- **សកម្មភាពឧស្សាហកម្ម ៖** នៅលើពិភពលោកនេះ មូលហេតុដ៏ធំបំផុតមួយដែលនាំឱ្យមានការបំពុលបរិស្ថានក្នុងខ្យល់ខ្លាំង គឺបណ្តាលមកពីកំណើននៃការប្រើប្រាស់វត្ថុធាតុដើមពីធម្មជាតិ និងអតុល្យភាពនៃប្រព័ន្ធអេកូឡូស៊ី។ សកម្មភាពឧស្សាហកម្មទាំងនេះបានបំភាយផ្សែងពុលឧស្ម័ន បញ្ចេញកាកសំណល់គ្រោះថ្នាក់ និងសំណល់ឧស្សាហកម្មនានាដែលមិនបានគ្រប់គ្រងឱ្យបានត្រឹមត្រូវ។ល។
- **ការបោះចោលកាកសំណល់ ៖** សំណល់ផ្ទះបាយ និងសំណល់ពាណិជ្ជកម្មក៏បានបំពុលបរិស្ថានផងដែរ បើសិនជាយើងមិនទុកដាក់ និងគ្រប់គ្រងឱ្យបានត្រឹមត្រូវ ជាពិសេសការកម្ទេចចោលសំរាម។ ភាគច្រើនគេសង្កេតឃើញ ការកម្ទេចចោលសំរាមមាន ២ប្រភេទ គឺការដុតសំរាមចោល និងការកប់សំរាមចោល។
- **យានយន្ត ៖** ផ្សែងដែលចេញពីយានយន្តគ្រប់ប្រភេទ ជាពិសេសផ្សែងដែលចេញពីរថយន្តចាស់ៗ ជាដើម។
- **ការដុតឥន្ទនៈផូស៊ីល ៖** កំណើននៃការប្រើប្រាស់ឥន្ទនៈនៅក្នុងឧស្សាហកម្មនានា។
- **សំណល់កសិកម្ម ៖** ការប្រើប្រាស់ថ្នាំគីមីកសិកម្ម និងថ្នាំសម្លាប់សត្វល្អិតហួសកម្រិត។

### ១.២.៣.៣. គ្មានការបំពុលដី

ពីមួយឆ្នាំទៅមួយឆ្នាំ អត្រានៃការកើនឡើងនៃសំណល់សំរាមមានការកើនឡើងឥតឈប់ឈរជាលំដាប់ដែលវាបានបង្កផលប៉ះពាល់ដល់បរិស្ថាន ជាពិសេសគឺការប៉ះពាល់ដល់ការបំពុលដី។ អត្រានៃការកើនឡើងនេះបណ្តាលមកពីអត្រាមនុស្សមានការកើនឡើង ហើយអត្រាតម្រូវការចេះតែកើនឡើងបន្ថែមទៀត ប៉ុន្តែការរៀបចំគ្រប់គ្រង និងទុកដាក់សំរាមនៅមានកម្រិតនៅឡើយ។ នាពេលបច្ចុប្បន្ន មូលហេតុដែលនៃការបំពុលដីជាទូទៅឃើញមានកត្តាចំនួន៣គឺ៖

- **កត្តាមនុស្ស** ៖ វាជាកត្តាចំបងមួយនៃការបំពុលដី ដោយសារតែមនុស្សមួយចំនួនបានគ្រប់គ្រង និងទុកដាក់សំរាមឱ្យបានត្រឹមត្រូវ ដែលជាហេតុធ្វើឱ្យសំរាមនៅរាយប៉ាយនៅលើដី ហើយមួយចំនួនទៀតបានកម្ទេចសំរាមដោយយកទៅដុត ឬកប់ចោលក្នុងដី ជាដើម។

- **កត្តាឧស្សាហកម្ម** ៖ កត្តានេះដែរ ភាគច្រើនគឺពាក់ព័ន្ធទៅនឹងរោងចក្រ ដែលបង្ហូរទឹកស្អុយទៅលើដី ឬទឹកដែលបង្កឱ្យមានការបំពុល ជាពិសេសឧស្សាហកម្មធន់ធ្ងន់ជាច្រើន ដូចជា រោងចក្រផលិតសារជាតិគីមីលោហៈធាតុ និងក្រដាសជាដើម ផលិតផលទាំងអស់នេះ គឺសុទ្ធតែប៉ះពាល់ទៅដល់បរិស្ថាន។
- **កត្តាកសិកម្ម** ៖ ក្នុងវិស័យកសិកម្មភាគច្រើនទាក់ទងនឹងការប្រើប្រាស់ថ្នាំគីមីកសិកម្ម និងថ្នាំសម្លាប់សត្វល្អិតហួសកម្រិត។

### ១.២.៣.៤. គ្មានការបំពុលដោយសារសំណល់រឹងរាវ

ជារៀងរាល់ថ្ងៃ គឺមានសំរាមជាច្រើនដែលត្រូវបោះចោល ទោះបីជាសំរាមទាំងនោះជាប្រភេទណាក៏ដោយ បើសិនជាពុំចេះរៀបចំទុកដាក់សំរាមទាំងនោះឱ្យបានល្អទេ វាអាចធ្វើអោយមានមេរោគផ្សេងៗ ជាហេតុធ្វើឱ្យប៉ះពាល់ដល់ជីវិតមនុស្ស សត្វ និងរុក្ខជាតិ ព្រមទាំងអាចបណ្ដាលឱ្យមានការកកស្ទះប្រព័ន្ធលូរំដោះទឹកផងដែរ។ ការបំពុលដោយសំណល់រឹងរាវត្រូវបានគេបែងចែកជាពីរប្រភេទគឺ៖

- **សំណល់រឹង** ៖ គឺសំដៅដល់វត្ថុរឹង សារធាតុរឹង ឬវត្ថុកម្ទេចកម្ទីដែលគេលែងត្រូវការប្រើប្រាស់បោះបង់ចោល ឬតម្រូវឱ្យបោះបង់ចោល។[១៣] ជាទូទៅបញ្ហានៃការទុកដាក់សំរាម ការញែក ការវេចខ្ចប់ និងការបញ្ចេញសំរាមសំណល់រឹងភាគច្រើនមាននៅតាមបណ្ដាទីប្រជុំជននានា។ ហេតុនេះហើយ រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំដីកា ឬលិខិតបទដ្ឋាននានា ដើម្បីណែនាំអនុវត្តការសម្អាត ការញែក ការវិចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹងនៅទីប្រជុំជន ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈឆ្លើយតបទៅនឹងស្ថានភាពជាក់ស្ដែងនៃទីប្រជុំជននីមួយៗ និងត្រូវធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងសំណល់រឹងនៅទីប្រជុំជន និងលើកកម្ពស់សោភ័ណ្ឌភាព អនាម័យ និងបរិស្ថាននៅតាមទីប្រជុំជន។[១៤]
  - អនុវត្តការញែក និងការវេចខ្ចប់សំរាមសំណង់រឹង ដែលអាចប្រើប្រាស់ឡើងវិញ ឬកែច្នៃបានដាច់ដោយឡែកពីសំរាមសំណង់រឹង ដែលត្រូវបោះចោលទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។[១៥]
  - ត្រូវទទួលខុសត្រូវក្នុងការវេចខ្ចប់ដោយថង់ ឬការដាក់នៅក្នុងធុងសំរាមផ្ទាល់ខ្លួននូវសំរាមសំណល់រឹងនៅទីប្រជុំជន ដែលបានបង្កើតក្នុងលក្ខណៈហ្មត់ចត់មិនឱ្យលេចធ្លាយមិនឱ្យលេចជ្រាបទឹកស្អុយ

---

[១៣] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com

[១៤] អនុក្រឹត្យស្ដីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ១១៣អនក្រ.បក, ២៧ សីហា ២០១៥, មាត្រា១៩ កថាខណ្ឌទី១ (ចាប់ពីពេលនេះតទៅហៅថាអនុក្រឹត្យលេខ១១៣អនក្រ.បក)។

[១៥] អនុក្រឹត្យលេខ១១៣អនក្រ.បក, មាត្រា១៥។

ឬមិនឱ្យមានភាពក្លិនស្អុយក្នុងរយៈពេលនៃការទុកដាក់រង់ចាំការបញ្ចេញទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។[១៦]

- ត្រូវទទួលខុសត្រូវក្នុងការរក្សាទុកនូវកញ្ចប់ ឬធុងផ្ទុកសំរាមសំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬបរិវេននៃលំនៅដ្ឋាន អគារ ឬទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមពេលម៉ោងដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។ រដ្ឋបាលរាជធានី ក្រុង ខណ្ឌ ត្រូវចាត់វិធានការត្រួតពិនិត្យឱ្យបានម៉ឺងម៉ាត់លើការអនុវត្តការបញ្ចេញកញ្ចប់ ឬធុងផ្ទុកសំរាមសំណល់រឹងនៅទីប្រជុំជនទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈរង់ចាំការប្រមូល និងដឹកជញ្ជូនទៅតាមពេលម៉ោងដែលបានកំណត់។[១៧]
- ម្ចាស់សំរាមសំណល់រឹងនៅទីប្រជុំជន ដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាមសំណល់រឹងនៅទីប្រជុំជនត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកសំរាមសំណល់រឹងទីប្រជុំជនដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។[១៨]

- **សំណល់រាវ** ៖ សំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថាន ដែលបញ្ចេញមកពីសកម្មភាព ឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។[១៩] ចំពោះប្រភេទសំណល់រាវខ្លះត្រូវបានស្ថាប័នពាក់ព័ន្ធឱ្យបញ្ចេញពីអគារអាជីវកម្ម បុរីលំនៅស្ថាន ទីក្រុងរណប និងតំបន់រមណីយដ្ឋាន មណ្ឌលកំសាន្តចូលទៅក្នុងប្រព័ន្ធលូ ដែលភ្ជាប់ទៅនឹងស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់រួមមុនពេលបង្ហូរចូលទៅកាន់ប្រភពទឹកនានា និងប្រភេទសំណល់រាវខ្លះអាចបង្ហូរចូលក្នុងទឹកសាធារណៈដោយផ្ទាល់ ឬឆ្លងកាត់តាមប្រព័ន្ធលូ។[២០]

### ១.២.៣.៥. គ្មានការបំពុលដោយសម្លេង

ចំពោះប្រទេសកម្ពុជា ការបំពុលដោយសម្លេងមានតិចតួចបំផុត ដោយសារតែប្រជាពលរដ្ឋមួយចំនួនធំមានការយល់ដឹងច្រើនលើបញ្ហានេះ ប៉ុន្តែក៏មានការបំពុលដោយសម្លេងមួយចំនួនដែលប្រទេសកម្ពុជាកំពុងជួបប្រទះ ដូចជា ក្លឹបខារ៉ាអូខេ រោងចក្រ ការកែឆ្នៃបច្ចេកទេសសម្លេងលើយានយន្តគ្រប់ប្រភេទពុំត្រឹមត្រូវតាមស្តង់ដារបច្ចេកទេស ការដ្ឋានសាងសង់នានាជាដើម ដែលសម្លេងទាំងអស់នេះមានបង្កជាការរំញ័រ និងការរំខាន ហើយអាចប៉ះពាល់ប្រជាពលរដ្ឋដែលរស់នៅជិតតំបន់ទាំងនោះ។ ប្រភពនៃការបំពុលសម្លេងត្រូវបានបែងចែកជាពីរគឺ៖

[១៦] អនុក្រឹត្យលេខ១១៣អនក្រ.បក, មាត្រា១៦។

[១៧] អនុក្រឹត្យលេខ១១៣អនក្រ.បក, មាត្រា១៧។

[១៨] អនុក្រឹត្យលេខ១១៣អនក្រ.បក, មាត្រា១៨។

[១៩] អនុក្រឹត្យលេខ២៣៥អនក្រ.បក, មាត្រា៤ កថាខណ្ឌទី២។

[២០] អនុក្រឹត្យលេខ២៣៥អនក្រ.បក, តារាងឧបសម្ព័ន្ធទី១ និងទី២។

- **ប្រភពចល័ត** ៖ គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មាន យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសម្លេងគ្រប់ប្រភេទ។
- **ប្រភេទអចល័ត** ៖ គឺជាប្រភេទដែលស្ថិតនៅទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មាន រោងចក្រ សហគ្រាស ឃ្លាំងស្តុកសម្ភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំឡេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ។[២១]

មកទល់ពេលនេះ មានការកម្រិតស្តង់ដារបញ្ចេញសំឡេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកម្រិតកំណត់ស្តង់ដារសំឡេងអតិបរមាសម្រាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន។[២២] ម្យ៉ាងវិញទៀតក៏មានការហាមឃាត់ដាច់ខាតនូវការបង្កឱ្យមានសំឡេងមួយចំនួន ដែលមិនឆ្លើយតបទៅនឹងកម្រិតកំណត់ស្តង់ដារសំឡេងផងដែរ។[២៣]

[២១] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, លេខ៤២អនក្រ.បក, ១០ កក្កដា ២០០០, មាត្រា៣ (ចាប់ពីពេលនេះតទៅហៅថាអនុក្រឹត្យលេខ៤២អនក្រ.បក)។

[២២] អនុក្រឹត្យលេខ៤២អនក្រ.បក, មាត្រា៧។

[២៣] អនុក្រឹត្យលេខ៤២អនក្រ.បក, មាត្រា៩។

# ជំពូកទី២
# ការរៀបចំក្រុងឆ្លាតវៃនៅកម្ពុជា

# ជំពូកទី២
# ការរៀបចំទីក្រុងឆ្លាតវៃនៅកម្ពុជា

ពិភពលោកនៅក្នុងយុគសម័យបច្ចេកវិទ្យា បានកំពុងអភិវឌ្ឍយ៉ាងឆាប់រហ័សក្នុងកម្រិតដែលថេរ និងជឿនលឿនបំផុត។ ស្របពេលជាមួយគ្នានេះ ពិភពលោកក៏កំពុងតែប្រឈមនឹងកំណើនផ្សេងៗមួយចំនួនរួមមានកំណើនប្រជាជន តម្រូវការ និងហេដ្ឋារចនាសម្ព័ន្ធ ដែលជាកត្តាជំរុញឱ្យមានការបំផ្លិចបំផ្លាញដល់បរិស្ថានធម្មជាតិ។ ប៉ុន្តែវាមិនមែនមានន័យថា យើងត្រូវបញ្ឈប់កំណើននោះទេ។ ទីក្រុង ប្រជាជន និងបរិស្ថាន ត្រូវដើរទៅមុខទន្ទឹមគ្នា។ តើវាមានន័យយ៉ាងដូចម្តេច? ក្នុងន័យនេះបានសេចក្តីថាបញ្ហាប្រឈមនានាមិនមែនជាការរាំងស្ទះដែលបញ្ឈប់ការអភិវឌ្ឍឡើយ ដោយសារភាពជឿនលឿននៃបច្ចេកវិទ្យា ជាពិសេសនៅក្នុងបដិវត្តន៍ឧស្សាហកម្មទី៤.0 ដែលមានបច្ចេកវិទ្យាដ៏គួរអោយចាប់អារម្មណ៍បំផុត និងមិនធ្លាប់មានពីមុនមក។ ដំណោះស្រាយដែលបច្ចេកវិទ្យាទំនើបទាំងនេះផ្តល់ឱ្យគឺការកសាងទីក្រុងឆ្លាតវៃ។ ទោះជាយ៉ាងណាក្តីទីក្រុងទាំងអស់ចាំបាច់ត្រូវអភិវឌ្ឍបរិយាកាសនៅជុំវិញខ្លួន ដើម្បីបំពេញតាមបម្រែបម្រួលនៃតម្រូវការជាក់ស្តែង និងអាទិភាពរបស់ប្រជាជន។ តាមរយៈការដាក់បញ្ចូលនូវដំណោះស្រាយឆ្លាតវៃទៅក្នុងបរិយាកាសរស់នៅទីក្រុងនានា វាធ្វើឱ្យទីក្រុងទាំងនោះកាន់តែមានផលិតភាពជាងមុន ហើយបង្កើតជាបរិស្ថានមួយដែលគួរឱ្យចង់រស់នៅសម្រាប់ប្រជាជន និងការធ្វើជំនួញអាចរីកលូតលាស់បានលឿន។ ទីក្រុងឆ្លាតវៃមិនត្រឹមតែមានមូលដ្ឋានជាការផ្ទៃប្រឌិតប៉ុណ្ណោះទេ តែវាមានទាំងចីរភាព និងបរិយាប័ន្នផងដែរ។

## ២.១. ជំហានដំបូងឈានទៅរកការរៀបចំទីក្រុងឆ្លាតវៃនៅកម្ពុជា

### ២.១.១. ការរៀបចំប្លង់គោល

#### ២.១.១.១. សញ្ញាណទូទៅនៃការរៀបចំប្លង់គោល

**ក.ប្រវត្តិនៃការបង្កើតប្លង់គោល**

ដោយយោងតាមការស្រាវជ្រាវប្លង់គោលឆ្នាំ១៩៥០មួយគត់ ដែលអនុម័តជាផ្លូវការដោយក្រសួងនៅខែមេសា ឆ្នាំ១៩៥០ ដែលធ្វើឡើងដោយការិយាល័យសិក្សាគម្រោងរបស់លោក Chauchon។ ហើយប្លង់គោលនាពេលនោះ ជាប្លង់គោលតម្រង់ទិសអភិវឌ្ឍតំបន់ធំៗ ដូចជា ពហុកីឡដ្ឋានជាតិអូឡាំពិច តំបន់ទួលគោកតំបន់បុរីកីឡា និងតំបន់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ហើយនៅឆ្នាំ១៩៧០ មានការិយាល័យនគរូបនីយកម្មដែលដឹកនាំដោយ **លោក លុយ បានហាប់** ក៏មានបំណងរៀបចំក្រុងភ្នំពេញបន្ថែមទៀត តែមិនបានសម្រេច។ ឆ្នាំ១៩៩៣ មានការសិក្សាជាឯកសារគោលរបស់លោក Guy Lemarchand ស្តីពីគម្រោងប្លង់គោល Greater

Phnom Penh និងឆ្នាំ២០០២ ដល់ឆ្នាំ២០០៥ គម្រោងប្លង់គោលរាជធានីភ្នំពេញក្រោមកម្មវិធី FSP របស់សាធារណៈរដ្ឋបារាំង។

### ខ. និយមន័យ

ប្លង់គោលជាឯកសារ ឬគម្រោងដែលមានលក្ខណៈជាយុត្តិសាស្ត្រនៃការអភិវឌ្ឍរាជធានីដល់ឆ្នាំ២០៣៥។ ហើយជាប្លង់គ្រឹះសម្រាប់រៀបចំដែនដីនៃក្រុងនីមួយៗ ពីព្រោះថាប្លង់គោលជាអ្នកតម្រង់ទិសក្នុងការរៀបចំបែងចែកឬកំណត់ផ្ទៃដីសម្រាប់តំបន់សំណង់ តំបន់ទេសចរណ៍ តំបន់ឧស្សាហកម្ម តំបន់សណ្ឋាគារ កន្លែងសួនសាធារណៈ តំបន់ចាក់សំរាម តំបន់សាលារៀន តំបន់ដែលត្រូវការពារ តំបន់ដែលត្រូវអភិវឌ្ឍន៍។ល។ ប្លង់គោលជាទូទៅ គឺគេចែងអំពីទស្សនវិស័យនៃការអភិវឌ្ឍដីធ្លី ក្នុងតំបន់ខេត្ត ក្រុងតែប៉ុណ្ណោះ។ នៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ពុំទាន់ឃើញមានការឱ្យនិយមន័យណាមួយជាក់លាក់ទៅលើប្លង់គោលនេះ ប៉ុន្តែប្លង់នេះ ត្រូវបានយកមកប្រើប្រាស់នៅក្នុងច្បាប់ស្ដីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ នៅត្រង់មាត្រា៥ ដែលបានចែងថាគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ រាជធានីភ្នំពេញ ឬអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ខេត្ត ក្រុង នីមួយៗ ត្រូវគូសប្លង់គោលដើម្បីធ្វើការរៀបចំ និងអភិវឌ្ឍខេត្ត ក្រុងរបស់ខ្លួន ហើយការរៀបចំប្លង់គោលនេះទៀតសោត ត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ នឹងត្រូវកំណត់ដោយអនុក្រឹត្យ។ គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចរៀបចំប្លង់គោលសម្រាប់តំបន់ពិសេសណាដែលដាក់ជូនគណៈរដ្ឋមន្ត្រី ដើម្បីការពារនូវបេតិកភណ្ឌ ការពារបរិស្ថាន និងដើម្បីធានាអភិវឌ្ឍសេដ្ឋកិច្ច។ ចំពោះរាជធានីភ្នំពេញ ការរៀបចំប្លង់គោលត្រូវបង្កើតគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់សម្រាប់ក្រុងភ្នំពេញ ហើយគណៈកម្មាធិការនេះ ត្រូវដឹកនាំដោយប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងភ្នំពេញ ឬអភិបាល អភិបាលរង ព្រមទាំងអង្គភាពបច្ចេកទេសដែលមានសមត្ថកិច្ចចូលរួមជាសមាជិក។ ជាទូទៅប្លង់គោលនេះមិនត្រូវបានប្រជាពលរដ្ឋយកមកធ្វើជាកម្មវត្ថុនៃបណ្ដឹងតាមផ្លូវច្បាប់បានឡើយ ពីព្រោះប្លង់គោលចែងតែអំពីទស្សនៈវិស័យនៃការអភិវឌ្ឍដីធ្លីនៅក្នុងតំបន់ដែលត្រូវរៀបចំតែប៉ុណ្ណោះ ដូច្នេះភ្នាក់ងាររដ្ឋបាលដែលមានសមត្ថកិច្ចត្រូវធ្វើការពិនិត្យទៅលើអត្ថន័យនៃប្លង់គោលជាមុនសិនមុននឹងធ្វើការរៀបចំប្លង់ប្រើប្រាស់ដីធ្លី និងសំណង់តំបន់ណាមួយ។ រាល់ប្លង់ប្រើប្រាស់ដីធ្លី សំណង់ និងលិខិតអនុញ្ញាតសាងសង់ត្រូវគោរពទៅតាមប្លង់គោលជានិច្ច។

### ២.១.១.២. អត្ថប្រយោជន៍នៃប្លង់គោល

ការរៀបចំបង្កើតជាប្លង់គោលបានផ្ដល់អត្ថប្រយោជន៍ជាច្រើនដល់ការអភិវឌ្ឍក្រុងដែលមានដូចជា៖

- ធ្វើការសាងសង់មានបទដ្ឋានតាមការកំណត់របស់ប្លង់គោល
- រាល់ឧទ្យានសួនច្បារ រមណីយដ្ឋាន មហោស្រព ទីធ្លាកំសាន្ត ត្រូវបានសាងសង់ដោយមានសណ្ដាប់ធ្នាប់
- ទីក្រុងមានសោភ័ណ្ឌភាព គ្មានសំណង់អនាធិបតេយ្យមានអនាម័យ
- គ្មានភាពច្របូកច្របល់ សួនច្បារក្លាយជាស្ថានីយបូមប្រេង ឆ្នេរទន្លេដែលជាទីលានស្រូបយកខ្យល់អាកាសសម្រាប់បម្រើដល់ភ្ញៀវទេសចរណ៍
- ប្លង់គោល ជាប្លង់បង្ហាញពីសោភ័ណ្ឌភាពតំបន់សណ្ដាប់ធ្នាប់ មានបណ្ដាញផ្គត់ផ្គង់ទឹក បណ្ដាញលូបង្ហូរ ទឹកភ្លៀង និងទឹកស្អុយ មានបណ្ដាញអគ្គីសនី មានទីកំសាន្ត មានសាលារៀន ដីសម្រាប់កីឡដ្ឋាន ដីសម្រាប់រដ្ឋបាល ទីធ្លាសម្រាប់ពាណិជ្ជកម្ម និងវប្បធម៌។ ប្លង់គោលមានបំណងធ្វើយ៉ាងណាឱ្យអនាគតទីក្រុងទំនើបនឹងលេចឡើងទៅតាមលំនាំប្លង់គោល ដើម្បីការអភិវឌ្ឍរីកចម្រើនលុបបំបាត់សំណង់អនាធិបតេយ្យ។

### ២.១.១.៣. ឯកសារចំបងក្នុងនីតិនគរូបនីយវិទ្យា

#### ក. ច្បាប់រដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ជំពូកទី៥ និងជំពូកទី៦ មានមាត្រាជាច្រើនដែលចែងពីតួនាទីរបស់រដ្ឋដូចជាមាត្រា៥៨ រដ្ឋទទួលបន្ទុកការងារ "ការពារបរិស្ថាន និងសមតានៃធនធានធម្មជាតិ និងធ្វើគម្រោងការគ្រប់គ្រងដី ទឹក លំហអាកាស ខ្យល់ ប្រព័ន្ធអេកូឡូស៊ី ថាមពល ប្រេង ហ្គាស ថ្ម និងខ្សាច់ ត្រី និងធនធានក្នុងទឹក"[២៤] មាត្រា៦៩ នៃរដ្ឋធម្មនុញ្ញចែងថារដ្ឋមាន "កាតព្វកិច្ចក្នុងការថែរក្សា និងការពារបូជនីយដ្ឋានបុរាណនានា វត្ថុសិល្បៈបុរាណ និងរៀបចំកែលំអតំបន់ប្រវត្តិសាស្ត្រនានា"។[២៥] មាត្រា៦១ នៃរដ្ឋធម្មនុញ្ញចែងថា "រដ្ឋលើកទឹកចិត្តដល់ការអភិវឌ្ឍសេដ្ឋកិច្ចលើគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ដោយយកចិត្តទុកដាក់ដល់គោលនយោបាយ ធារាសាស្ត្រ អគ្គីសនី ការដឹកជញ្ជូន បច្ចេកទេស ទំនើប និងប្រព័ន្ធឥណទាន"[២៦] និងមាត្រា៤៤ ចែងថាការដកសិទ្ធិនេះពីបុគ្គលម្នាក់អាចធ្វើបានតែក្នុងករណីហេតុផលនៃប្រយោជន៍សាធារណៈ ដែលមានចែងក្នុងច្បាប់តែប៉ុណ្ណោះ ហើយលុះណាតែមានការកាត់សំណងសមស្របណាមួយផ្ដល់ឱ្យជាមុនទៀត។[២៧] ដូចនេះ តួនាទីរបស់រដ្ឋ គឺសម្រួលដំណើរការនៃទីផ្សារដោយដាក់ឱ្យអនុវត្តនូវគោលនយោបាយ ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខាចាំបាច់ទាំងឡាយដើម្បីពង្រឹងសមត្ថភាពការអភិវឌ្ឍសេដ្ឋកិច្ច។

---

[២៤] ព្រះរាជណាចក្រកម្ពុជា, "រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា", ២៤ កញ្ញា ១៩៩៣, ភ្នំពេញ, មាត្រា៥៨។
[២៥] ព្រះរាជណាចក្រកម្ពុជា, "រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា", ២៤ កញ្ញា ១៩៩៣, ភ្នំពេញ, មាត្រា៦៩។
[២៦] ព្រះរាជណាចក្រកម្ពុជា, "រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា" , ២៤ កញ្ញា ១៩៩៣, ភ្នំពេញ, មាត្រា៦១។
[២៧] ព្រះរាជណាចក្រកម្ពុជា, "រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា" , ២៤ កញ្ញា ១៩៩៣, ភ្នំពេញ, មាត្រា៤៤។

**ខ. លិខិតបទដ្ឋាននានា**

ច្បាប់ និងបទដ្ឋាននានាដែលទាក់ទងនឹងប្លង់គោលៈ

- ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ឆ្នាំ១៩៩៤

មាត្រា១ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ មានកម្មវត្ថុជំរុញឱ្យមានការរៀបចំកែលម្អទីក្រុង និងតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាកិច្ចអភិវឌ្ឍសុខដុមនៃប្រទេសក្នុងស្មារតីៈ

- គោរពប្រយោជន៍រួម និងប្រយោជន៍បុគ្គលផង គោរពសិទ្ធិឯកជនផង គោរពបញ្ញាច្បាប់ផង និងត្រួតពិនិត្យការសាងសង់ផង។
- ការធានាការអភិវឌ្ឍសំដៅរកលំនឹងរវាងទីក្រុង និងតំបន់ជនបទ ផ្អែកលើភូមិសាស្ត្រ និងលក្ខណៈពិសេសនៃជនបទនីមួយៗ។
- ធានាលើតម្លៃសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌ និងធានាការអភិវឌ្ឍវិស័យសេដ្ឋកិច្ច វិស័យទេសចរណ៍ និងរក្សាបាននូវគុណភាពបរិស្ថាន។

មាត្រា៤ ឯកសារទាំងឡាយដែលទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ត្រូវរៀបចំតាមករណីនីមួយៗ ឱ្យសមស្របទៅតាមស្ថានភាពលក្ខណៈពិសេសនៃទឹកដីខេត្ត-ក្រុង តំបន់ក្នុងស្មារតីការពារដល់បេតិកភណ្ឌ បរិស្ថានការពារធនធានធម្មជាតិ ព្រមទាំងធានាដល់ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច។

ដើម្បីការពារនូវបេតិកភណ្ឌការពារបរិស្ថាន និងដើម្បីធានាអភិវឌ្ឍសេដ្ឋកិច្ចចំពោះតំបន់ពិសេសណាមួយដែលគណៈរដ្ឋមន្ត្រីបានកំណត់គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ មានភារៈរៀបចំប្លង់គោលសម្រាប់តំបន់ពិសេសនោះដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត។

មាត្រា៨ ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ត្រូវតែគោរពតាមប្លង់គោលដូចមានចែងក្នុងមាត្រា៥ នៃច្បាប់នេះ។

មាត្រា១៣ មិនអនុញ្ញាតឱ្យសាងសង់នូវសំណង់ណា ក្នុងលក្ខណៈដែលមិនសមស្របនឹងប្លង់គោល ឬប្លង់ប្រើប្រាស់ដីធ្លី និងសំណង់។

មិនអនុញ្ញាតឱ្យសាង់សង់ បើគម្រោងសាងសង់នោះមានការប៉ះពាល់ដល់សន្តិសុខ សាធារណៈ ប៉ះពាល់ដល់បរិស្ថាន ប៉ះពាល់ដល់អនាម័យសាធារណៈ សំណង់ ឬអចលនវត្ថុ ដែលមានសារៈប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណ្ឌភាព បច្ចេកទេស ឬប៉ះពាល់ដល់តំបន់ដែលមានធនធានធម្មជាតិ។

មិនអនុញ្ញាតឱ្យសាងសង់ បើសិនជាមានការរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធ បរិក្ខាសាធារណៈឱ្យបាន គ្រប់គ្រាន់ និងគម្រោងសំណង់ដែលសុំ។

- សារាចរណែនាំស្តីពីការរៀបចំគម្រោងប្លង់គោលនៅតាមខេត្ត-ក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជា, លេខ០២សរ. ១៥ មករា ១៩៩៦

- អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់, លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧

មាត្រា៣២ តំបន់មិនអាចសាងសង់បានខេត្ត និងក្រុងនីមួយៗ ត្រូវកំណត់បានជាបន្ទាន់នូវប្លង់តំបន់មិនអាចសាងសង់បាន។ ប្លង់នេះ ត្រូវមានបញ្ចូលតំបន់ការពារធម្មជាតិ តំបន់កសិកម្ម តំបន់ព្រៃឈើ និងរ៉ែដែលគោលដៅប្រើប្រាស់ពុំអាចប្រើប្រាស់ពុំអាចផ្លាស់ប្តូរបានដោយមូលហេតុផលប្រយោជន៍សេដ្ឋកិច្ចនិងបរិស្ថាន។

ប្លង់នេះត្រូវមានបញ្ចូលរមណីយដ្ឋានធម្មជាតិ ដូចជាឆ្នេរសមុទ្រ មាត់ទន្លេ ព្រែក ស្ទឹង បឹងបួ ដោយមូលហេតុផលប្រយោជន៍បេតិកភណ្ឌ និងបរិស្ថាន។

ប្លង់នេះត្រូវមានបញ្ចូលគ្រប់តំបន់អាចលិចទឹក ដែលត្រូវការពារដោយមូលហេតុជាផលប្រយោជន៍សម្រាប់បង្ហូរទឹកភ្លៀងចេញ និងការប្រយុទ្ធប្រឆាំងនឹងទឹកជំនន់។

អាជ្ញាធរតាមមូលដ្ឋានត្រូវចាត់វិធានការសមស្របដើម្បីការពារ និងបង្កើតគុណសម្បត្តិតំបន់មិនអាចសាងសង់បានទាំងនោះ។ រាល់លិខិតអនុញ្ញាតសាងសង់ មិនផ្តល់ជូនឡើយក្នុងតំបន់ទាំងនោះ។

ក្នុងករណីមានការសាងសង់ដោយល្មើសច្បាប់ ក្នុងតំបន់ហាមឃាត់ទាំងនេះ អាជ្ញាធរដែនដីត្រូវបង្ខំឱ្យជនល្មើសរុះរើដោយខ្លួនឯង ហើយធ្វើឱ្យកន្លែងនោះមានសភាពដូចដើមវិញ ក្នុងរយៈកាលមួយកំណត់។

ក្នុងករណីមិនអនុវត្តតាមការកំណត់ អាជ្ញាធរដែនដីត្រូវធ្វើការជាកពិន័យ និងចាត់ឱ្យរុះរើ និងធ្វើឱ្យកន្លែងនោះមានសភាពដូចដើមវិញ ដោយចាប់បង្ខំឱ្យអ្នកល្មើសច្បាប់ ត្រូវចេញសោហ៊ុយចំណាយទាំងអស់ ឬក្នុងករណីចាំបាច់ប្តឹងទៅតុលាការ ដើម្បីឱ្យចេញដីកាកិច្ចការប្រញាប់បញ្ជាឱ្យរុះរើ។

ប្លង់នេះ ត្រូវទទួលបានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងត្រូវផ្សព្វផ្សាយជាសាធារណៈដល់មន្ត្រីរាជការផ្នែកអាជ្ញាធរដែនដីមូលដ្ឋាន និងមន្ត្រី ជំនាញទទួលខុសត្រូវលើ "តំបន់មិនអាចសាងសង់បាន" ដែលពុំបានចាត់វិធានការចាំបាច់ ដើម្បីឱ្យមានការគោរពតំបន់ទាំងនោះទេត្រូវទទួលទណ្ឌកម្មរដ្ឋបាលតាមច្បាប់ជាធរមាន។

មាត្រា៤៨ ជាការដាក់បន្ថែមដល់បទបញ្ជាទូទៅនៃការប្រើប្រាស់ដីធ្លី ការណែនាំមួយចំនួនសម្រាប់ការរៀបចំ និងបទបញ្ជានគរូបនីយកម្មពិសេសមួយចំនួន អាចត្រូវតាក់តែងឡើងដោយអនុក្រឹត្យដែលអាចមានរហូតដល់ការហាមមិនឱ្យសាងសង់ក្នុង "តំបន់ចាប់អារម្មណ៍" ដូចជា ឆ្នេរសមុទ្រ មាត់ច្រាំងទន្លេ និងបឹងធំៗ។

រាល់ឯកសារ "នគរូបនីយកម្មមូលដ្ឋាន" និងប្លង់ខេត្តនៃតំបន់ហាមមិនឱ្យមានសំណង់ដែលចែងក្នុងមាត្រា៣២ វគ្គទី២ នៃអនុក្រឹត្យនេះត្រូវទុកជាការណែនាំ និងការហាមជាយថាហេតុមិនឱ្យសាងសង់។

- ច្បាប់ភូមិបាល ឆ្នាំ២០០១
- អនុក្រឹត្យ៨៦ អនក្រប.បក ស្តីពីនីតិវិធីនៃការសាងសង់ប្លង់សុរិយោដី និងសៀវភៅ គោលបញ្ជីដីធ្លី ឆ្នាំ២០០២
- អនុក្រឹត្យលេខ៨៧ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការសុរិយោដី ឆ្នាំ២០២០
- អនុក្រឹត្យលេខ៨៨ អនក្រ.បក ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ឆ្នាំ២០០២
- ច្បាប់ស្តីពីការរៀបចំខេត្តក្រុងឆ្នាំ១៩៩៤
- ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ឆ្នាំ១៩៩៦

មាត្រា១ ច្បាប់នេះមានគោលដៅថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិ និងសម្បត្តិវប្បធម៌ទូទៅប្រឆាំងនឹងការបំផ្លិចបំផ្លាញ ការប្រែក្លាយ ការប្តូររូបរាង ការជីករុករក ការផ្ទេរកម្មសិទ្ធិ ការនាំចេញ និងការនាំចូលដោយខុសច្បាប់។

មាត្រា៦ រមណីដ្ឋានដែលត្រូវការពាររួមមាន៖

- ឧទ្យានដែលមានបុរាណវត្ថុ ឬរមណីដ្ឋានដទៃទៀត ដែលមានអត្ថប្រយោជន៍សម្រាប់បុរាណវិទ្យាឬប្រវត្តិវិទ្យាអាចធ្វើការកំណត់ព្រំដែនបាន។
- ព្រំដែននៃបរិវេណរមណីដ្ឋានដែលត្រូវការពារត្រូវកំណត់ដោយ ព្រះរាជក្រឹត្យតាមសំណើរបស់ក.ជ.វ.ជ។

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ នសរ/រកម/០៣០១/00៥ ឆ្នាំ២០០១

មាត្រា៥ ឃុំសង្កាត់គ្រប់គ្រងកិច្ចការមូលដ្ឋានក្នុងដែនដីរបស់ខ្លួន ដោយផ្អែកទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។

អំណាចបញ្ញត្តិ អំណាចប្រតិបត្តិក្នុងការគ្រប់គ្រងមូលដ្ឋានត្រូវផ្តល់ឱ្យឃុំ សង្កាត់ ហើយអំណាចនេះត្រូវអនុវត្តស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។

មាត្រា៦ ការបង្កើត ការលុបចោល ការកែប្រែព្រំដែនព្រំប្រទល់ និងការប្តូរឈ្មោះរបស់ឃុំសង្កាត់ក្នុងករណីមិនប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្តក្រុងពាក់ព័ន្ធ ត្រូវសម្រេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីមហាផ្ទៃ។

ក្នុងករណីដែលមានប៉ះពាល់ដល់ព្រំប្រទល់ខេត្ត ក្រុងពាក់ព័ន្ធការបង្កើតការលុបចោលការកែប្រែព្រំប្រទល់ និងការប្តូរឈ្មោះរបស់ឃុំសង្កាត់ត្រូវសម្រេចដោយព្រះក្រឹត្យ តាមសំណើរបស់នាយរដ្ឋមន្ត្រីផ្អែកលើសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

- ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, នស/រកម/០៦៩៩/០៩/២៣ មិថុនា ១៩៩៩

មាត្រា១ អនុក្រឹត្យនេះកំណត់ការរៀបចំបណ្តាអង្គភាពរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងកំណត់បេសកម្មរបស់ក្រសួង និងមុខការរបស់បណ្តាអគ្គនាយកដ្ឋាន នាយកដ្ឋាននានា និងអង្គភាពមូលដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា។

- ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

មាត្រា១ ច្បាប់នេះមានគោលដៅ៖

- ការពារលើកកម្ពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋដោយធ្វើការទប់ស្កាត់ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុល
- វាយតម្លៃហេតុប៉ះពាល់បរិស្ថានមុននឹងចេញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ចំពោះរាល់គម្រោងដែលបានស្នើឡើង
- ធានាឱ្យមានការអភិរក្សការអភិវឌ្ឍការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផលនឹងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា
- លើកទឹកចិត្តនឹងផ្តល់លទ្ធភាពឱ្យសាធារណៈជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានជាតិ
- បង្ក្រាបអំពើទាំងឡាយណាដែលធ្វើឡើងឱ្យប៉ះពាល់ដល់បរិស្ថាន។

- អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការបំពុលដោយការរំខានដោយសំឡេងឆ្នាំ២០០០
- ប្រកាសស្តីពីការបំរុងទុកនូវទីតាំងនានាសម្រាប់ផ្លូវថ្នល់ និងផ្លូវដែក
- សារាចរលេខ០២ ចុះថ្ងៃ១៥ ខែមករា ឆ្នាំ១៩៩៦ របស់ខុទ្ទកាល័យនៃទីស្តីការគណៈរដ្ឋមន្ត្រី
- អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៧

មាត្រា២ ដោយឈរលើមូលដ្ឋាននៃច្បាប់ និងបទដ្ឋានជាធរមាន និងក្របខ័ណ្ឌនៃនគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចដូចតទៅ៖

- ណែនាំ និងកំណត់ទិសដៅក្នុងការរៀបចំប្លង់គោលរបស់រាជធានីភ្នំពេញ និងខេត្តក្រុង ដើម្បីការពារធនធានធម្មជាតិនានា ដី ទឹក ខ្យល់ ព្រៃឈើ ទេសភាព និងសម្បត្តិវប្បធម៌ ឬបេតិកភណ្ឌជាតិ
- ចងក្រងគោលនយោបាយ សម្រាប់លើកកម្ពស់សម្បជញ្ញៈរបស់ប្រជារាស្ត្រឱ្យរួមចំណែកក្នុងការអភិវឌ្ឍវិស័យផ្សេងៗ ដូចជាសង្គមកិច្ច សេដ្ឋកិច្ច វប្បធម៌ទាំងនៅជនបទទាំងនៅទីក្រុង
- ណែនាំធ្វើការសិក្សា ដើម្បីបង្កើតប្លង់តាមភាគផ្នែកៗ ក្នុងទីរួមខេត្ត និងក្រុងនានា ដោយសម្របសម្រួលទៅតាមល័ក្ខខ័ណ្ឌនៃទីកន្លែង
- តាមដាន និងពិនិត្យមើលសំណង់គ្រប់ប្រភេទ ដើម្បីឱ្យស្របជាមួយបរិស្ថានធម្មជាតិ
- គ្រោងតំបន់រក្សាទុក ដើម្បីបម្រើឱ្យសេចក្តីត្រូវការនាពេលអនាគតសម្រាប់អភិវឌ្ឍគ្រប់សកម្មភាពឱ្យអនុលោមទៅតាមប្លង់គោល
- កំណត់ឱ្យការពារ និងថែរក្សាទុកឱ្យទំនេរតំបន់ជុំវិញមាត់ឆ្នេរតំបន់ជុំវិញមាត់ឆ្នេរសមុទ្រ មាត់ទន្លេ មាត់ជ្រោះ មាត់អូរ និងមាត់ព្រែក ព្រមទាំងបឹងត្រពាំង ផ្លូវទឹក ទំនប់ អនុលោមទៅតាមការកំណត់របស់ប្លង់គោល ដើម្បីទុកឱ្យប្រជាពលរដ្ឋប្រើប្រាស់ទឹកដោយសេរី និងសម្រាប់ការធ្វើដំណើរ
- កំណត់ព្រំដែនលំនៅឋានសម្រាប់សកម្មភាពសេដ្ឋកិច្ច វប្បធម៌ រដ្ឋបាល ទៅតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ដោយរៀបចំបណ្តាយចែកចាយទឹក និងអគ្គីសនី ផ្លូវគមនាគមន៍ ការដឹកជញ្ជូន ព្រមជាមួយការពារបរិស្ថានដោយបំបាត់ក្លិនអាក្រក់ ភាពកខ្វក់ និងការរំខានបណ្តាលមកពីសូរសំឡេងជាដើម
- កំណត់តំបន់ហាមឃាត់ការបោះទីតាំង និងសំណង់នៅទីកន្លែងសាធារណៈ និងទីកន្លែងជាផលប្រយោជន៍ទូទៅដូចជា សាលារៀន ទីលានកីឡា សួនច្បារ ផ្លូវថ្នល់សាធារណៈ ដីចំណីសងខាងផ្លូវសាធារណៈបរិវេណវត្តអារាម គ្រឹះស្ថានសុខាភិបាល ដីចំណីសងខាងផ្លូវដែក បណ្តាញលូទឹក ។ល។
- សហការជាមួយបណ្តាក្រសួង មន្ទីរ និងអង្គភាពពាក់ព័ន្ធដើម្បីតាក់តែងគម្រោងច្បាប់ និងអត្ថបទច្បាប់ទាក់ទងនឹងក្រុងភ្នំពេញ ជនបទ និងក្រុងនានា ហើយដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងដាក់ស្នើសុំការអនុម័តពីសភាជាតិ។
- ចាត់ចែងការអប់រំប្រជាពលរដ្ឋឱ្យម្នាក់ៗ ភ្ញាក់រឭកចំពោះករណីយកិច្ចរបស់ខ្លួន និងចូលរួមចំណែកក្នុងការការពារបរិស្ថាន និងការលំអទេសភាពនៅរាជធានីក៏ដូចជានៅតាមទីប្រជុំជន ទីក្រុង និងជនបទ

- សម្របសម្រួលការងារបច្ចេកទេស និងកិច្ចការផ្សេងៗទៀតដល់គណៈកម្មាធិការ និងបណ្តាអនុគណៈកម្មាធិការខេត្ត-ក្រុង តាមច្បាប់ និងបទប្បញ្ញត្តិជាធរមានតាមលទ្ធភាព និងតម្រូវការជាក់ស្តែង។

• អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៩

មាត្រា២ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែតំបន់ណា ឬសមត្ថកិច្ចណាដែលរាជរដ្ឋាភិបាលប្រគល់ឱ្យស្ថាប័នមួយផ្សេងទៀត។

### ២.១.២. ការរៀបចំផែនការសម្រាប់ទីក្រុងឆ្លាតវៃនៅកម្ពុជា

#### ២.១.២.១. ចរាចរណ៍ឆ្លាតវៃ

ជាការពិតណាស់ ដើម្បីអភិវឌ្ឍទីក្រុងមួយឱ្យសម្រេចបានជាទីក្រុងវៃឆ្លាតនោះគឺត្រូវមានការរៀបចំនៅហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ សំណង់នានាឱ្យមានបច្ចេកវិទ្យាទំនើប។ ក្នុងនោះផងដែរការរៀបចំការធ្វើចរាចរណ៍ឱ្យមានភាពឆ្លាតវៃ ក៏ជាចំណុចសំខាន់មួយក្នុងការអភិវឌ្ឍទីក្រុងវៃឆ្លាតផងដែរ។ បច្ចេកវិទ្យាសម្រាប់ការធ្វើចរាចរណ៍ឆ្លាតវៃបានបង្កើតឡើងនៅសាកលវិទ្យាល័យ Carnegie Mellon University និងបានដាក់ឱ្យសាកល្បងនៅទីក្រុង Pittsburgh ក្នុងសហរដ្ឋអាមេរិច ដើម្បីកាត់បន្ថយការបំភាយផ្សែងពុលរបស់យានយន្តដែលធ្វើដំណើរលើដងវិថី។ វាគឺជាភ្លើងសញ្ញាចរាចរណ៍ឆ្លាតវៃ ដែលខុសពីធម្មតាដែលគេបានដាក់តែទិន្នន័យឱ្យដំណើរការដោយស្វ័យប្រវត្តិប៉ុណ្ណោះទេ តែវាជាភ្លើងសញ្ញាចរាចរណ៍ឆ្លាតវៃ ដែលបានអភិវឌ្ឍក្នុងយុគ្គសម័យចុងក្រោយនេះ។ វាបានបូកបញ្ចូលទាំងបច្ចេកវិទ្យាដែលមានស្រាប់ និងបច្ចេកវិទ្យាបញ្ញាសិប្បនិមិត្ត (Artificial Intelligent) ដោយប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ។ ប្រព័ន្ធពីរនេះមានទំនាក់ទំនងគ្នា និងសម្របទៅតាមការផ្លាស់ប្តូរគ្រប់ស្ថានភាពចរាចរណ៍ ដើម្បីកាត់បន្ថយរយៈពេលដែលយានយន្តធ្វើដំណើរ និងឈប់រង់ចាំដោយមានបំពាក់ប្រព័ន្ធឆ្លាតវៃដែលអាចកំណត់ចំនួនយានយន្ត អ្នកធ្វើដំណើរថ្មើរជើង និងប្រព័ន្ធផ្លាស់ប្តូររយៈពេលដោយស្វ័យប្រវត្តិតាមពេលវេលាជាក់ស្តែងដើម្បីបញ្ចៀសការកកស្ទះចរាចរណ៍នៅកន្លែងដែលអាចធ្វើទៅបាន។ លទ្ធផលដំបូងដែលទទួលបាននោះគឺ ចំនួនពេលវេលាដែលអ្នកបើកបរយានយន្តទំនេរក្នុងពេលឈប់រង់ចាំភ្លើងសញ្ញាចរាចរណ៍ត្រូវបានកាត់បន្ថយចំនួន៤០% ហើយពេលវេលាធ្វើដំណើរឆ្លងកាត់ទីក្រុងបានកាត់បន្ថយចំនួន២៥%។ វាពិតជាមានសារៈសំខាន់ណាស់សម្រាប់ការបញ្ចៀសការកកស្ទះចរាចរណ៍ និងកាត់បន្ថយការបំពុលដែលភាយចេញពីយានយន្តផងដែរ។

**២.១.២.២. ភ្លើងបំភ្លឺផ្លូវឆ្លាតវៃ**

បន្ទាប់ពីមានចរាចរណ៍ឆ្លាតវៃរួចហើយ ភ្លើងបំភ្លឺឆ្លាតវៃក៏ជាធាតុផ្សំសំខាន់មួយក្នុងការអភិវឌ្ឍទីក្រុងឆ្លាតវៃផងដែរ។ ភ្លើងបំភ្លឺផ្លូវឆ្លាតវៃសំដៅទៅលើភ្លើងបំភ្លឺផ្លូវសាធារណៈ ដែលសម្របទៅនឹងចលនារបស់អ្នកដំណើរថ្មើរជើង អ្នកដំណើរដោយជិះកង់ និងយានយន្តនានា ដោយវាបំពាក់ប្រព័ន្ធឧបករណ៍ចាប់សញ្ញា (Sensor) កំណត់ដោយស្វ័យប្រវត្តិនៅពេលមានអ្នកដំណើរឆ្លងកាត់វាបើកបំភ្លឺ និងបិទទៅវិញនៅពេលគ្មានអ្នកដំណើរ។ បន្ថែមពីនេះទៀតភ្លើងបំភ្លឺឆ្លាតវៃបានផ្តល់នៅអត្ថប្រយោជន៍មួយចំនួនផ្សេងទៀតផងដែរ។ វាអាចប្រើដើម្បីលើកកម្ពស់សន្តិសុខ សុវត្ថិភាពក្នុងទីក្រុង ក៏ដូចជាការបំពាក់បន្ថែមនូវកាមេរ៉ាសុវត្ថិភាព និងកំណត់ចំនួនទិន្នន័យអ្នកធ្វើដំណើរ ហើយអាចបង្កើនគុណភាពជីវិតរស់នៅប្រចាំថ្ងៃ ដោយកំណត់នូវម៉ោងដែលវាត្រូវភ្លឺដោយស្វ័យប្រវត្តិនោះសកម្មភាពនឹងអាចកើតមានឡើង។ ចំណុចដែលគួរអោយចាប់អារម្មណ៍អំពីភ្លើងបំភ្លឺឆ្លាតវៃគឺវាអាចបំពាក់ប្រព័ន្ធអ៊ីនធឺណិត (Wi-Fi) និងកន្លែងសាកថ្មទូរស័ព្ទជាដើម ដើម្បីផ្តល់ភាពងាយស្រួលដល់ការទំនាក់ទំនងរបស់អ្នកដំណើរ។ មិនត្រឹមតែធ្វើអោយជីវិតពោរពេញទៅដោយបច្ចេកវិទ្យា ម្យ៉ាងវិញទៀតភ្លើងបំភ្លឺឆ្លាតវៃក៏អាចលំអរសោភ័ណ្ឌភាពពេលយប់ក្នុងទីក្រុងបានមួយចំណែកធំផងដែរ។

**២.១.២.៣. ចំណតឆ្លាតវៃ**

បន្ទាប់ពីមានភ្លើងបំភ្លឺឆ្លាតវៃ និងចរាចរណ៍ឆ្លាតវៃរួចហើយ ធាតុផ្សំសំខាន់មួយទៀតនោះ គឺចំណតឆ្លាតវៃ។ ពីព្រោះកាលណានៅតែមានការចតយានយន្តបំពាន អនាធិបតេយ្យ និងគ្មានសណ្តាប់ធ្នាប់វានឹងនៅតែបង្កឱ្យមានការកកស្ទះចរាចរណ៍ដដែល។ កន្លែងចតយានយន្តឆ្លាតវៃ គឺជាយុទ្ធសាស្ត្រដែលរួមបញ្ចូលបច្ចេកវិទ្យាទំនើប និងការឆ្នៃប្រឌិតរបស់មនុស្សក្នុងការធ្វើឱ្យមានការសន្សំសំចៃប្រេងពេលវេលាឱ្យបានតិចបំផុត និងទីធ្លាដើម្បីទទួលបានចំណតលឿន ងាយស្រួល និងមានសុវត្ថិភាពចំពោះយានយន្ត។ ចំណតឆ្លាតវៃបានបំពាក់នូវប្រព័ន្ធសេនស័រ (Sensors) ដែលអាចឱ្យដឹងពីចំណតដែលទំនេរតាមរយៈកម្មវិធីក្នុងទូរស័ព្ទស្មាតហ្វូន។ ចំណតឆ្លាតវៃអាចលេចឡើងក្នុងទម្រង់ផ្សេងៗគ្នា ទៅតាមការឆ្នៃប្រឌិតរបស់មនុស្សដូចជាចំណតឆ្លាតវៃតាមផ្លូវសាធារណៈ ចំណតឆ្លាតវៃក្រោមដី ឬក៏ចំណតឆ្លាតវៃ ដែលមានទំហំតូចតែខ្ពស់អាចចតរថយន្តបានច្រើនគ្រឿងជាដើម។ ចំណតឆ្លាតវៃមានដើរតួយ៉ាងសំខាន់ក្នុងការបញ្ចៀសការកកស្ទះចរាចរណ៍ និងសោភ័ណ្ឌភាពក្នុងទីក្រុង និងកាត់បន្ថយការចំណាយទៅលើប្រេងឥន្ធនៈផងដែរ។

**២.១.២.៤. ប្រព័ន្ធកាមេរ៉ាឆ្លាតវៃ**

ក្រៅពីចរាចរណ៍ ភ្លើងបំភ្លឺ និងចំណតឆ្លាតវៃ ប្រព័ន្ធកាមេរ៉ាឆ្លាតវៃក៏ជាធាតុផ្សំសំខាន់មួយក្នុងការធានានូវសន្តិសុខ សុវត្ថិភាពរបស់ប្រជាជន និងបង្កើតជាទីក្រុងឆ្លាតវៃផងដែរ។ នៅក្នុងទីក្រុងឆ្លាតវៃត្រូវការប្រព័ន្ធកាមេរ៉ា

សុវត្ថិភាពឆ្លាតវៃដែលអាចត្រួតពិនិត្យ និងចាប់រូបភាពបានគ្រប់ជ្រុងជ្រោយគ្រប់ផ្លូវក្នុងទីក្រុង ដើម្បីធានាដល់ទិន្នន័យក្នុងការធ្វើដំណើរចេញចូលក្រុង និងបញ្ចៀសឱ្យបាននូវការកកស្ទះចរាចរណ៍។ ប្រព័ន្ធកាមេរ៉ាសុវត្ថិភាពមានផលប្រយោជន៍ដូចជា៖

- កាត់បន្ថយការកកស្ទះចរាចរណ៍ប្រចាំថ្ងៃ ដោយធ្វើឱ្យលំហូរចរាចរណ៍មានភាពរលូន និងផ្តល់អាទិភាពដល់ចរាចរណ៍ដើម្បីឆ្លើយតបនឹងតម្រូវការ និងពេលវេលាជាក់ស្តែង
- កាត់បន្ថយការបំពុលបរិស្ថាននៅទូទាំងទីក្រុង
- វាក៏នឹងផ្តល់នូវការតំឡើងឧបករណ៍ត្រួតពិនិត្យ ដើម្បីប្រមូលទិន្នន័យចរាចរណ៍ និងទិន្នន័យលំអិតបន្ថែមទៀតដើម្បីទប់ស្កាត់បទល្មើសនានាដែលបង្កឡើងនៅលើដងផ្លូវ

**២.១.២.៥. ការគ្រប់គ្រងកាកសំណល់ឆ្លាតវៃ**

ជាការពិតណាស់ ការគ្រប់គ្រងកាកសំណល់ពិតជាមានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍទីក្រុងឱ្យមានអនាម័យ និងសោភ័ណ្ឌភាព។ នៅក្នុងគម្រោងរៀបចំទីក្រុងឆ្លាតវៃគេក៏ត្រូវការការគ្រប់គ្រងកាកសំណល់ឆ្លាតវៃផងដែរ។ ការគ្រប់គ្រងកាកសំណល់ឆ្លាតវៃមានន័យថា ជាការវិចខ្ចប់ ទុកដាក់ ប្រមូល និងកម្ទេចសំរាមដោយប្រើប្រព័ន្ធបច្ចេកវិទ្យាឆ្លាតវៃ។ ការប្រើប្រាស់ធុងសំរាមឆ្លាតវៃត្រូវបានប្រទេសអភិវឌ្ឍជាច្រើននៅលើពិភពលោកបាននឹងកំពុងដាក់ឱ្យប្រើប្រាស់ និងទទួលបានលទ្ធផលគួរកត់សំគាល់។ ធុងសំរាមឆ្លាតវៃមានអត្ថប្រយោជន៍ជាច្រើនដូចជា៖

- វានឹងផ្តល់សញ្ញាដោយស្វ័យប្រវត្តិដល់អ្នកប្រមូលសំរាមនៅពេលដែលសំរាមពេញធុង
- ដំណើរការប្រមូលសំរាមតិចជាងមុនដែលនឹងកាត់បន្ថយការកកស្ទះ និងការរំខានចរាចរណ៍ដែលជាហេតុឱ្យផ្លូវស្អាត និងមានសុវត្ថិភាពផងដែរ
- កាត់បន្ថយការទុកសំរាមចោលយូរក្នុងធុង ដែលបណ្តាលឱ្យមានក្លិនមិនល្អចេញមកក្រៅ
- ការកាត់បន្ថយចរាចរណ៍ដោយសារតែការប្រមូលផ្តុំតិចជាងមុនជួយកាត់បន្ថយកាបូនឌីអុកស៊ីត និងការបំភាយផ្សេងៗ

ធុងសំរាមឆ្លាតវៃ ត្រូវបានធ្វើឡើងឱ្យមានលក្ខណៈស្តង់ដារដើម្បីឱ្យវាអាចសំអាតខ្លួនឯងដោយឧបករណ៍ដែលមានស្រាប់ និងអាចបំពាក់មកជាមួយនឹងឧបករណ៍ភ្ជាប់អ៊ីធឺណិតដែលផ្តល់អោយទីក្រុងកាន់តែមានសោភ័ណ្ឌភាព និងទំនាក់ទំនង។ ក៏ប៉ុន្តែ ផ្ទុំផ្តុំនឹងការប្រើប្រាស់ធុងសំរាមឆ្លាតវៃប្រជាពលរដ្ឋត្រូវមានការយល់ដឹងអំពីវិចខ្ចប់ និងទុកដាក់សំរាមផងដែរ ដោយគួរគប្បីលុបបំបាត់ឱ្យបាននៅការចោលសំរាមពាសវាលពាសកាលការវិចខ្ចប់មិនបានត្រឹមត្រូវ និងការមិនយកចិត្តទុកដាក់ក្នុងការរៀបចំសំរាមជាដើម។

## ២.១.៣. មាត្រដ្ឋានស្តង់ដារនៃសំណង់

### ២.១.៣.១. ទំនើបកម្មនៃសំណង់

ការអភិវឌ្ឍទីក្រុងមួយឱ្យមានភាពឆ្លាតវៃ គេត្រូវការសំណង់អគារដែលមានភាពទំនើបប្រកបដោយបច្ចេកវិទ្យាជឿនលឿន និងរស់រវើក។ មូលដ្ឋានគ្រឹះសម្រាប់ការសាងសង់សំណង់អគារឱ្យមានភាពទំនើប គឺគេត្រូវសាងសង់ដោយប្រើបច្ចេកវិទ្យា ដើម្បីចែករំលែកព័ត៌មានពីអ្វីៗដែលកំពុងកើតមានក្នុងអគារ និងប្រព័ន្ធនានា ដើម្បីធ្វើឱ្យដំណើរការនៅក្នុងអគារកាន់តែមានភាពរស់រវើក និងឆ្លាតវៃ។ ការសាងសង់សំណង់អគារដែលឱ្យមានភាពទំនើបស្ថាបត្យករត្រូវគិតពីគុណភាពខ្យល់ដែលមិនអោយសាងសង់នៅចំណុចដែលធ្វើអោយប៉ះពាល់ដល់គុណភាពខ្យល់ដែលត្រូវបក់ចូលក្រុង។ ប្រព័ន្ធសន្តិសុខ អនាម័យត្រូវមានការត្រួតពិនិត្យជាប្រចាំ និងមានស្តង់ដារខ្ពស់។ កាត់បន្ថយការប្រើប្រាស់ថាមពលច្រើនដូចជាការប្រើប្រាស់ភ្លើងច្រើនដោយឥតប្រយោជន៍។ ការលំអភ្លើងនៅខាងក្រៅអគារក៏ជាកត្តាដែលធ្វើឱ្យសំណង់អគារមានភាពស្រស់ស្អាតផងដែរ និងបានធ្វើឱ្យសោភ័ណ្ឌភាពពេលយប់ដល់ទីក្រុងផងដែរ។ បន្ថែមពីនេះទៀត ការកែលម្អអគារចាស់ៗឱ្យទៅជាអគារដែលមានភាពល្អប្រសើរ និងទំនើបបំពាក់ទៅដោយបច្ចេកវិទ្យាឆ្លាតវៃក៏ជាកត្តាចាំបាច់មួយក្នុងការអភិវឌ្ឍទីក្រុងទៅជាទីក្រុងឆ្លាតវៃផងដែរ។

### ២.១.៣.២.ប្រណិតភាពនៃហេដ្ឋារចនាសម្ព័ន្ធ

មិនខុសគ្នាពីសំណង់អគារ ប្រណិតភាពនៃហេដ្ឋារចនាសម្ព័ន្ធក៏ជាកត្តាសំខាន់ក្នុងការអភិវឌ្ឍទីក្រុងផងដែរ។ ហេដ្ឋារចនាសម្ព័ន្ធគឺជាពាក្យបច្ចេកទេសមួយ ដែលប្រើសម្រាប់រៀបរាប់អំពីមធ្យោបាយក៏ដូចជាគ្រឿងប្រដាប់សម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅសម័យទំនើបរបស់មនុស្សយើងតួយ៉ាងដូចជា បណ្តាញទឹក គេហដ្ឋាន ផ្លូវថ្នល់ បណ្តាញខ្សែកាប សាលារៀន មន្ទីរពេទ្យ ព្រលានយន្តហោះ ទីជួបជុំសាធារណៈ អគាររដ្ឋាភិបាល ស្ពាន ផ្លូវដែក ជាដើម។ ហេដ្ឋារចនាសម្ព័ន្ធមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងកម្រិតជីវភាព និងការប្រើប្រាស់ហួសកំរិត។ រាល់ពេលដែលប្រជាជនកើនឡើងទ្វេដងរចនាសម្ព័ន្ធត្រូវការទ្វេរដង ឬច្រើនជាងនេះ។ ការកសាងហេដ្ឋារចនាសម្ព័ន្ធឱ្យមានភាពប្រណិតគឺជារឿងដ៏ស្មុកស្មាញមួយក្នុងការអភិវឌ្ឍទីក្រុង ហេតុនេះដើម្បីឱ្យទីក្រុងមានភាពទំនើប និងមានប្រណិតភាពអ្នកសាងសង់ត្រូវមានភាពឆ្នៃប្រឌិតខ្ពស់ និងការដាក់បញ្ចូលនូវបច្ចេកវិទ្យាជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់។ ឧទាហរណ៍ ការសាងសង់ផ្លូវដែលភ្ជាប់មកជាមួយនឹងភ្លើងសញ្ញាចរាចរណ៍ឆ្លាតវៃ ការសាងសង់សំណង់ត្រឹមត្រូវតាមមាត្រដ្ឋានស្តង់ដារ ការសាងសង់សួនច្បារតាមដងផ្លូវនានា ការដាក់ភ្លើងបំភ្លឺឆ្លាតវៃ ការសាងសង់ស្ពានអាកាស រថភ្លើងក្រោមដី ឬលើអាកាសជាដើមដោយបំពាក់ជាមួយបច្ចេកវិទ្យាឆ្លាតវៃ។

### ២.១.៣.៣. ប្រណិតភាពនៃទំនើបកម្មសម្រាប់ការរស់នៅ

ការមានកន្លែងរស់នៅឱ្យមានភាពល្អប្រសើរ និងមានផាសុខភាពជារឿងចាំបាច់បំផុតសម្រាប់មនុស្ស ក៏ប៉ុន្តែនៅក្នុងយុគ្គសម័យនេះមនុស្សត្រូវការការរស់នៅដែលផ្តល់នូវភាពប្រណិត និងប្រកបទៅដោយបច្ចេកវិទ្យាថ្មីៗទំនើបៗ។ មានការកសាង និងបង្កើតកន្លែងរស់នៅសម្ភារៈ និងទីកន្លែង ដែលមានភាពទំនើប និងប្រណិតភាពជាច្រើនបានត្រូវបានលេចរូបរាងនៅក្នុងទីក្រុងជុំវិញពិភពលោក ក៏ដូចជានៅក្នុងព្រះរាជាណាចក្រកម្ពុជាបាននឹងកំពុងអភិវឌ្ឍ។ ប្រណិតភាពនៃទំនើបកម្មសម្រាប់ការរស់នៅគឺជាការភ្ជាប់ជីវិតរស់នៅជាមួយ និងបច្ចេកវិទ្យាថ្មីៗ ឧទាហរណ៍ ដូចជាការផ្លាស់ប្តូរពីធុងសំរាមចាស់ៗ មកប្រើប្រាស់បច្ចេកវិទ្យាចុងក្រោយដែលបានលើកឡើងក្នុងចំណុចខាងលើ ឬក៏ការផ្លាស់ប្តូរទម្លាប់រស់នៅពីការរស់នៅផ្ទះមកជាការរស់នៅក្នុងខុនដូរ ឬអាផាតមិនទំនើបរបស់ប្រជាជន។ ទាំងអស់នេះជាកត្តាសំខាន់បំផុតសម្រាប់ការអភិវឌ្ឍពីទីក្រុងធម្មតាមួយទៅជាទីក្រុងឆ្លាតវៃ។

## ២.២. អនាគតទីក្រុងឆ្លាតវៃនៅកម្ពុជា

### ២.២.១. និន្នាការនៅរកទីក្រុងឆ្លាតវៃ

ទោះជាយ៉ាងណាក៏ដោយ គេឃើញមានការកើនឡើងនៃចំណាប់អារម្មណ៍នឹងការរីកសាយនៃការអនុវត្តគម្រោងទីក្រុងឆ្លាតវៃនៅទូទាំងពិភពលោកមិនថាប្រទេសអភិវឌ្ឍនឹងកំពុងអភិវឌ្ឍ ដែលនិន្នាការនេះបានសាយភាយពីទ្វីបអឺរ៉ុបទៅដល់អាមេរិច អាស៊ីបូព៌ា និងអាហ្វ្រិក ក្នុងគោលបំណងបង្កើតទីក្រុងដែលមានទាំងចីរភាព និងប្រសិទ្ធភាព។ យោងតាមការស្រាវជ្រាវលើទីផ្សាររបស់ទីក្រុងវៃឆ្លាត (គេបានព្យាករណ៍ថាតម្លៃទីផ្សារទីក្រុងឆ្លាតវៃនឹងកើនឡើងពី ៤៤២,៨៩ ពាន់លានដុល្លារ ឆ្នាំ២០១៧) ទៅដល់ ១.២២៦,៦៨ ពាន់លានដុល្លារ ត្រឹមឆ្នាំ២០២៣ ដែលមានអត្រាកំណើនប្រចាំឆ្នាំចំនួន ១៨,២២ ភាគរយ (Mordor Intelligence,nd)។ ជាមួយគ្នានេះ ការចំណាយទូទាំងពិភពលោកលើការអភិវឌ្ឍទីក្រុងឆ្លាតវៃត្រូវបានគេរំពឹងថានឹងឡើងដល់ ៣៤,៣៥ ពាន់លានដុល្លារក្នុងឆ្នាំ២០២០។ ក្នុងចំណោមទីផ្សារទីក្រុងឆ្លាតវៃទូទាំងពិភពលោក តំបន់អាស៊ីប៉ាស៊ីហ្វិកត្រូវបានគេព្យាករណ៍ថានឹងមានអត្រាកំណើនលឿន និងខ្ពស់បំផុត ហើយមួយចំណែកធំនៃកំណើននេះគឺនៅក្នុងប្រទេសចិន និងឥណ្ឌា ដែលបច្ចុប្បន្នមានគម្រោងទីក្រុងឆ្លាតវៃប្រមាណ ៥០០ និង ៧៥០ រៀងៗខ្លួន។ ក្នុងតំបន់អាស៊ីអាគ្នេយ៍វិញ ដូចដែលគេបានដឹងហើយថា សិង្ហបុរី បើទោះបីជាខ្វះខាតធនធានធម្មជាតិយ៉ាងណាក្តី ក៏សេដ្ឋកិច្ចរបស់ប្រទេសនេះត្រូវបានទទួលស្គាល់ថាជាសេដ្ឋកិច្ចមួយក្នុងចំណោមសេដ្ឋកិច្ចដែលរីកលូតលាស់យ៉ាងឆាប់រហ័សបំផុត និងជាគំរូអភិវឌ្ឍដែលទទួលបានជោគជ័យ ជាពិសេសសម្រាប់ការកសាងទីក្រុងឆ្លាតវៃ។ យោងតាមសន្ទស្សន៍ទីក្រុងឆ្លាតវៃ (Smart City Index) សិង្ហបុរីបានជាប់ចំណាត់ថ្នាក់លេខ១ ក្នុងចំណោម

បណ្តាប្រទេសដែលកំពុងប្រើប្រាស់បច្ចេកវិទ្យាទីក្រុងឆ្លាតវៃដែលការវាយតម្លៃនេះ ផ្តែកលើលក្ខខណ្ឌវិនិច្ឆ័យចំនួន០៤ ដែលរួមមានចល័តភាពសេវាសុខាភិបាល សុវត្ថិភាពសាធារណៈ និងផលិតកម្មសាធារណៈ ក្នុងគោលបំណងផ្តល់នូវសេវាកម្មល្អប្រសើរ និងលើកកម្ពស់គុណភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋ។ ទំនោរនេះ ក៏បានទាក់ទាញដល់ប្រទេសកម្ពុជា និងអង្គការក្នុងតំបន់ផងដែរ។ បណ្តាញទីក្រុងវៃឆ្លាតអាស៊ាន ( ASEAN Smart Cities Network) ត្រូវបានបង្កើតឡើងនៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣២ នៅខែមេសា ឆ្នាំ២០១៨ គឺជាវេទិកាមួយដែលទីក្រុងនានារបស់សមាជិកអាស៊ាន បានបង្កើតកិច្ចប្រតិបត្តិសហការក្នុងការកសាង និងអភិវឌ្ឍភាពឆ្លាតវៃ និងចីរភាព សម្រាប់ទីក្រុងរបស់ពួកគេ។

### ២.២.២. គម្រោងរៀបចំទីក្រុងឆ្លាតវៃនៅកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចយករាជធានី និងទីក្រុងចំនួនពីរផ្សេងទៀតដើម្បីដាក់បញ្ចូលជាទីក្រុងក្នុងបណ្តាញទីក្រុងឆ្លាតវៃអាស៊ានកាលពីឆ្នាំ២០១៩។ ទីក្រុងកម្ពុជាចំនួនបីនោះគឺ រាជធានីភ្នំពេញ ក្រុងបាត់ដំបង និងក្រុងសៀមរាប ស្ថិតនៅក្នុងចំណោមទីក្រុងសាកល្បងចំនួន២៦ ដែលត្រូវបានផ្តល់ជំនួយសម្រាប់គម្រោងបង្កើតទីក្រុងឆ្លាតវៃនៅក្រោមបណ្តាញទីក្រុងឆ្លាតវៃនៅអាស៊ាននេះ ដែលនឹងត្រូវទទួលជំនួយពីរដ្ឋាភិបាលជប៉ុនក្នុងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យានានា ដើម្បីសម្រេចសមិទ្ធផលទីក្រុងនេះអោយខានតែបាន។ យ៉ាងណាក្តីទស្សនៈវិស័យរដ្ឋាភិបាលសម្រាប់ទីក្រុងឆ្លាតវៃ ត្រូវបានយកចិត្តទុកដាក់តាំងពីឆ្នាំ២០១៦មកម្លេះ ក្នុងគម្រោងរួមគ្នាមួយជាមួយកូរ៉េខាងត្បូង ដើម្បីធ្វើឱ្យទីក្រុងព្រះសីហនុក្លាយជាទីក្រុងឆ្លាតវៃ។ ទាក់ទងនឹងបញ្ហានេះ ផែនការមេសម្រាប់រាជធានីភ្នំពេញឆ្នាំ២០៣៥ ត្រូវបានបង្កើតឡើងដើម្បីគាំទ្រការអភិវឌ្ឍទីក្រុងទំនើបនៅរាជធានីភ្នំពេញ និងដោយយោងតាមទស្សនទានទីក្រុងឆ្លាតវៃក្នុងបំណងធានាឱ្យបាននូវការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ស្របពេលដែលមានការរីកចម្រើនផ្នែកនគរូបនីយកម្ម ដែលត្រូវបានគេរំពឹងថាត្រឹមឆ្នាំ២០៣០ នឹងមានប្រជាជនប្រមាណ៨លាននាក់ រស់នៅក្នុងទីក្រុងទោះយ៉ាងណាក៏ដោយការកសាងទីក្រុងឆ្លាតវៃទាមទារឱ្យមានការខិតខំប្រឹងប្រែងរួមគ្នាពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ មិនមែនត្រឹមតែរដ្ឋាភិបាលនោះទេ ប៉ុន្តែរួមទាំងសហគ្រាស អ្នកវិទ្យាសាស្ត្រ និងសាធារណជន ព្រោះថាទីក្រុងឆ្លាតវៃមិនមែនជានីតិវិធីពីលើចុះក្រោម ឬពីក្រោមឡើងលើទេ គឺត្រូវមានទាំងពីរបូកបញ្ចូលគ្នា។ គម្រោងអភិវឌ្ឍទីក្រុងបុរាណសៀមរាបត្រូវបានលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំរវាងរដ្ឋបាលខេត្តសៀមរាប និងភាគីជប៉ុនកាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០កន្លងទៅ។ កិច្ចប្រជុំនេះធ្វើឡើងក្នុងគោលបំណងដើម្បីពិនិត្យលទ្ធភាពក្នុងការចាប់ផ្តើមសិក្សាគម្រោងទីក្រុងឆ្លាតវៃសៀមរាប ដែលមានគោលដៅអភិវឌ្ឍទីក្រុងនេះអោយក្លាយជាទីក្រុងទំនើបឆ្លាតវៃហើយមានកម្រិតស្តង់ដារស៊ីវិល័យដូចទីក្រុងទំនើបឆ្លាតវៃនានាទាំងនៅលំដាប់តំបន់ និងសកល

លោកផងដែរ។ ផែនការសកម្មភាពអនុវត្តជាក់លាក់នៅមិនទាន់កំណត់អោយដឹងនៅឡើយទេ ទោះជាយ៉ាងណាក្តី យោងតាមទំព័រហ្វេសប៊ុកផ្លូវការរបស់រដ្ឋបាលខេត្តសៀមរាបបានអោយដឹងថា ក្រុមការងារទាំងពីរនឹងបន្តជួបគ្នាដើម្បីសិក្សាលើគម្រោងនេះអោយបានស៊ីជម្រៅបន្ថែមទៀត ដើម្បីអោយគម្រោងអភិវឌ្ឍឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់ទីក្រុង និងស្ថានភាពអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស និងលំហូរចូលនូវទេសចរណ៍ខេត្តសៀមរាប។ ខណៈពេលដែលរដ្ឋាភិបាលបង្កើតគោលនយោបាយផ្តោតលើកម្មវិធីទីក្រុងឆ្លាតវៃ និងផ្តល់ធនធានចាំបាច់ក្នុងការអនុវត្តគោលនយោបាយ សហគ្រាស និងអ្នកវិទ្យាសាស្ត្រ ត្រូវបង្កើនកិច្ចខិតខំប្រឹងប្រែងបង្កើតនឹងធ្វើបច្ចុប្បន្នភាពបច្ចេកវិទ្យាដើម្បីស្របទៅតាមកិច្ចប្រឹងប្រែង គោលនយោបាយ នឹងចក្ខុវិស័យរបស់រដ្ឋាភិបាល។ រីឯសាធារណជន ក្រៅពីការប្រើប្រាស់ឱ្យអស់លទ្ធភាពលើសេវាកម្មនឹងបច្ចេកវិទ្យាទំនើបៗដែលផ្តល់ជូនពួកគេក៏មានតួនាទីចូលរួមក្នុងអភិបាលកិច្ច និងការគ្រប់គ្រងទីក្រុងឆ្លាតវៃឱ្យបានសកម្មដែរដែលនេះត្រូវបានគេស្គាល់ថាជាការចូលរួមបែបអេឡិចត្រូនិច។

### ២.២.៣. ភាពអវិជ្ជមាននៃទីក្រុងឆ្លាតវៃ

បញ្ហាមួយដ៏តានតឹងបំផុតដែលទីក្រុងឆ្លាតវៃត្រូវដោះស្រាយ និងយកចិត្តទុកដាក់ គឺការការពារសុវត្ថិភាព និងឯកជនភាព។ ដោយសារតែទីក្រុងឆ្លាតវៃត្រូវការទិន្នន័យបើកចំហ និងមានតម្លាភាព ការការពារទិន្នន័យដ៏ធំនឹងស្មុកស្មាញពីការវាយប្រហារនានាគឺពិតជាបញ្ហាប្រឈមដ៏ធំបំផុតមួយ។ សំខាន់ជាងនេះទៅទៀត វាមិនត្រឹមតែផ្ទុកនូវទិន្នន័យរបស់អ្នកប្រើប្រាស់ប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងមាននូវទិន្នន័យរសើបរបស់រដ្ឋាភិបាលផងដែរ។ ដោយសារតែប្រព័ន្ធប្រតិបត្តិការទិន្នន័យ និងការគ្រប់គ្រងព័ត៌មាន មានភាពស្មុគស្មាញ និងប្រទាក់ក្រឡាគ្នានៅក្នុងប្រព័ន្ធទាំងមូល និងការប្រាស្រ័យទាក់ទងជារួម។ ប្រសិនបើអ្នកវាយប្រហារយកព័ត៌មានដែលទទួលបាននោះមកប្រើប្រាស់ក្នុងផ្លូវទុច្ចរិត វានឹងនាំមកនូវមហន្តរាយដ៏ធំធេងដែលមិនអាចនឹកស្មានដល់។ ករណីបែបនេះបានកើតឡើងនៅឆ្នាំ២០១៨ នៅពេលមានការវាយប្រហារតាមអ៊ីនធឺណិតលើប្រព័ន្ធកុំព្យូទ័រសាធារណៈនៅអាត្លង់តា ដែលជាទីក្រុងមួយល្បីល្បាញក្នុងការវិនិយោគនៅក្នុងប្រព័ន្ធឆ្លាតវៃ។ ការវាយប្រហារបានធ្វើឱ្យមានការកាត់ផ្តាច់ប្រតិបត្តិការមួយចំនួនធំក្នុងទីក្រុងទាំងនោះ ដែលក្នុងនោះការផ្អាកប្រតិបត្តិការខ្លះមានដល់ទៅរាប់ខែឯណោះ (Unal,2019)។ សម្រាប់អ្នកវាយប្រហារតាមអ៊ីនធឺណិតទីក្រុងឆ្លាតវៃប្រៀបដូចជាទីតាំងនៃក្តីសុបិនមួយសម្រាប់ពួកគេធ្វើសកម្មភាពវាយប្រហារ។ បញ្ហាមួយទៀតដែលត្រូវយកពិចារណាដូចគ្នាគឺការរំលោភលើសិទ្ធិឯកជនរបស់អ្នកប្រើប្រាស់។ សកម្មភាពទាំងអស់របស់អ្នកប្រើប្រាស់សុទ្ធសឹងតែត្រូវបានរក្សាទុក និងត្រួតពិនិត្យមិនថាតាមរយៈកាមេរ៉ាឆ្លាតវៃ ឬឃ្លាំងទិន្នន័យនោះទេ។ ក្នុងករណីនេះអ្នកប្រើប្រាស់ពុំមានអារម្មណ៍សុវត្ថិភាពឡើយ ព្រោះពួកគេត្រូវបានគេឃ្លាំមើលគ្រប់សកម្មភាពមិនថាកន្លែងដែលគេទៅអ្វីដែលគេញ៉ាំ ឬទិញ

ក៏ដូចជាអ្វីដែលគេផ្ញើសារឱ្យគ្នាទៅវិញទៅមកនោះទេ។ មិនត្រឹមតែប៉ុណ្ណោះ ពួកគេមិនទាំងដឹងថា តើទិន្នន័យរបស់ពួកគេកំពុងត្រូវបានគេតាមដានប្រើប្រាស់ លក់បន្ត ឬយកទៅធ្វើអ្វីនោះទេ ដែលបង្កើតបាននូវភាពមិនច្បាស់លាស់មួយចេញពីបច្ចេកវិទ្យាទាំងនេះ គឺការបូកបញ្ចូលគ្នារវាងភាពងាយស្រួលក្នុងជីវិតរស់នៅប្រចាំថ្ងៃ និងការបាត់បង់ ឯកជនភាពរបស់មនុស្ស។ ក្រៅពីបញ្ហាទិន្នន័យ និងព័ត៌មាន ក៏មានការព្រួយបារម្ភពីសមភាពនៃការអភិវឌ្ឍ ដោយកើតចេញពីការផ្តោតសំខាន់ហួសហេតុទៅលើទីក្រុងឆ្លាតវៃ។ ទីក្រុងឆ្លាតវៃត្រូវបានគេទទួលស្គាល់ថាជាគម្រោងទាមទារឱ្យមានទុនចំណាយដ៏ខ្ពស់លើការអភិវឌ្ឍបច្ចេកវិទ្យា ដែលត្រូវប្រើប្រាស់ធនធានដ៏ធំធេងទាំងបច្ចេកទេស និងថវិកា ក្នុងការកសាងទីក្រុងឆ្លាតវៃមួយ។ ស្របពេលដែលមានការចំណាយយ៉ាងច្រើនលើសលុបតំបន់ផ្សេងទៀតនឹងត្រូវលះបង់ឱកាសក្នុងការអភិវឌ្ឍ និងរីកលូតលាស់ ដែលជាលទ្ធផល និងបង្កើតឱ្យមានគម្លាតនៃការអភិវឌ្ឍ។ បញ្ហាចុងក្រោយ ទីក្រុងឆ្លាតវៃអាចដំណើរការដោយរលូនបានគឺអាស្រ័យលើការផ្គត់ផ្គង់អគ្គីសនី។ បើថាមពលអគ្គីសនីត្រូវបានកាត់ផ្តាច់ទីក្រុងឆ្លាតវៃប្រាកដជាលែងឆ្លាតទៀតហើយ។

### ២.២.៤. ដំណោះស្រាយ

នាពេលថ្មីៗនេះទីក្រុងឆ្លាតវៃបានក្លាយជាវិធីសាស្ត្រដ៏សំខាន់បំផុតសម្រាប់នគរូបនីយកម្ម។ គ្រោះមហន្តរាយផ្សេងដែលអាចកើតមានទៅលើទិន្នន័យគឺជារឿងដែលគ្រោះថ្នាក់បំផុតសម្រាប់ទីក្រុងឆ្លាតវៃ ហេតុនេះតើគួរមានវិធានការអ្វីខ្លះចំពោះបញ្ហានេះ។ វិស័យគមនាគមន៍ និងទូរគមនាគមន៍ ត្រូវដើរតួរយ៉ាងសំខាន់សម្រាប់ការការពារគ្រោះថ្នាក់ផ្សេងៗទៅលើទិន្នន័យលើប្រព័ន្ធអ៊ីនធឺណិត។ ប្រព័ន្ធឆ្លើយតបបន្ទាន់ និងភាពរឹងមាំនៃកន្លែងផ្ទុកទិន្នន័យជាវិមាត្រដ៏សំខាន់បំផុតសម្រាប់ការរចនាទីក្រុងឆ្លាតវៃ និងទៅអនាគតដោយសារតែកំណើននៃការរំខានផ្សេងៗពីមនុស្ស និងគ្រោះមហន្តរាយធម្មជាតិ។ ដូចជាឧទាហរណ៍ ដែលបានលើកឡើងនៅចំណុចខាងលើវាពិតជាមានគ្រោះថ្នាក់ខ្លាំងណាស់ ប្រសិនបើប្រព័ន្ធទូរគមនាគមន៍ខ្សោយ។ ដូចនេះវិស័យទូរគមនាគមន៍ត្រូវមានភាពឆ្លាតវៃដែលអាចដើរទន្ទឹមគ្នាបានជាមួយ និងការលូតលាស់នៃទីក្រុងឆ្លាតវៃ។ ដំណោះស្រាយមួយវិញទៀតគឺការការពារពីការទទួលរងគ្រោះមហន្តរាយធម្មជាតិដែលកើតមានដោយឯកឯងដូចជា រញ្ជួយដី ទឹកជំនន់ ឬស៊ូណាមិជាដើម។ វិស័យគមនាគមន៍ត្រូវមានវិធានការលើបញ្ហាគ្រប់គ្រងគ្រោះមហន្តរាយដែលប្រើប្រព័ន្ធដឹកជញ្ជូនឆ្លាតវៃ ដើម្បីគ្រប់គ្រងគ្រោះមហន្តរាយបានទាន់ពេលវេលា។ ដើម្បីឱ្យទីក្រុងឆ្លាតវៃដំណើរការទៅបាននោះរាជរដ្ឋាភិបាលគួរតែយកចិត្តទុកដាក់លើការអភិវឌ្ឍវិស័យទាំងពីរនេះអោយមានភាពខ្លាំង និងសមស្របទៅតាមភាពជឿនលឿននៃបច្ចេកវិទ្យានាសម័យទំនើបនេះ។

# សេចក្តីសន្និដ្ឋាន

យោងតាមការបកស្រាយខាងលើ យើងសង្កេតឃើញថា ដើម្បីអាចរៀបចំទីក្រុងមួយឱ្យក្លាយទៅជាទីក្រុងឆ្លាតវៃនៅកម្ពុជា អាជ្ញាធរ អង្គភាពពាក់ព័ន្ធត្រូវតែបំពេញកិច្ចការការងារជាច្រើន ជាពិសេសគឺត្រូវរៀបចំឱ្យមានប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ជាមុន ព្រោះថាប្លង់គោលជាឯកសារមួយដែលមិនអាចខ្វះបានក្នុង វិស័យនគរូបនីយកម្ម ដែលប្រៀបបានជាច្បាប់មួយដែលរាល់សំណង់ទាំងអស់មុនត្រូវបានអនុញ្ញាតសាងសង់ ត្រូវតែគោរពតាមប្លង់គោលនេះជាដាច់ខាត បើមិនដូច្នេះទេសំណង់ទាំងនោះមិនត្រូវបានអនុញ្ញាតឱ្យសាងសង់ឡើយ ហើយបើនៅតែសាងសង់ទៀតនោះម្ចាស់សំណង់នឹងត្រូវទទួលនូវទណ្ឌកម្មនានាជាក់ជាមិនខាន។ ចំពោះប្លង់ប្រើប្រាស់ដីធ្លី និងសំណង់វិញ ក៏មានសារៈសំខាន់ដែរ ព្រោះថាប្លង់នេះបានកំណត់យ៉ាងច្បាស់អំពីតំបន់ ដែលត្រូវប្រើប្រាស់សម្រាប់ការពារជាតិ សម្រាប់កសិកម្ម សម្រាប់ពាណិជ្ជកម្ម សម្រាប់ ឧស្សាហកម្ម សិប្បកម្ម វប្បធម៌ ទេសចរណ៍ សាសនា ព្រមទាំងសម្រាប់សំណង់នៃរដ្ឋបាល និងបរិក្ខារសាធារណៈ។ ម្យ៉ាងវិញ ទៀតប្លង់នេះកំណត់ផងដែរនូវលទ្ធភាពសាងសង់ ព្រមទាំងត្រូវគោរពតាមប្លង់គោល។

សរុបសេចក្តីមកយើងអាចសន្និដ្ឋានបានថា ទោះបីជាទីក្រុងនៅកម្ពុជាបច្ចុប្បន្នពុំទាន់មានការរៀបចំជាទីក្រុងឆ្លាតវៃក៏ដោយ ក៏ប៉ុន្តែរាជរដ្ឋាភិបាល អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអង្គភាពពាក់ព័ន្ធនៅតែខិតខំរៀបចំផែនការនៃការរៀបចំអភិវឌ្ឍទីក្រុងឆ្លាតវៃនៅកម្ពុជាជាជំហានៗ តាមរយៈការរៀបចំផែនការរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើយ៉ាងណាប្រែក្លាយទីក្រុងនៅកម្ពុជាទៅជាទីក្រុងឆ្លាតវៃនាពេលអនាគត។

# អនុសាសន៍

យោងតាមការសង្កេតមើលពីស្ថានភាពជាក់ស្តែងការរៀបចំទីក្រុងឆ្លាតវៃនៅកម្ពុជា យើងខ្ញុំសង្កេតឃើញថាវាមានការលំបាកក្នុងការរៀបចំប្លង់មេដោយតំបន់ខ្លះមានសាងសង់ខុសពីប្លង់មេ ប៉ុន្តែការមានប្លង់មេមួយគឺជាការល្អប្រសើរជាងការគ្មានប្លង់មេ។ ប្លង់មេសម្រាប់ទីក្រុងឆ្លាតវៃមួយ គឺមិនមែនគ្រាន់តែជាគោលការណ៍ណែនាំអំពីក្រាហ្វិក ឬវិធានសម្រាប់ការអភិវឌ្ឍនោះទេ វាគឺជាការសិក្សាហ្មត់ចត់នៃកំណើនសង្គម និងសេដ្ឋកិច្ចនៃទីក្រុងនេះ ទីក្រុងសម្រាប់អ្នកទាំងអស់គ្នា កំណើនក្រុមវណ្ណៈកណ្តាល កំណើនគ្រួសារ កំណើនចរាចរណ៍ និងកំណើនសម្ពាធសម្រាប់ជីវិតក្នុងទីក្រុង។ ខ្ញុំចង់ឃើញទីក្រុងភ្នំពេញជាទីក្រុងឆ្លាតវៃរៀបចំឡើងដោយមានប្រសិទ្ធភាព និងជាកន្លែងមួយដែលមានតុល្យភាពរវាងជីវិត ការងារ និងគ្រួសារ។ ខ្ញុំមិនគិតថា វាជាការយឺតពេលដើម្បីការផ្លាស់ប្តូរទីក្រុងនេះ ដោយសារយើងនៅតែស្ថិតក្នុងដំណាក់កាលនៃការចាប់ផ្តើមការសាងសង់នៅឡើយ ខ្ញុំសង្ឃឹមថានឹងបានឃើញអគារដែលមានការរចនាចំពោះការអភិវឌ្ឍលំនៅដ្ឋាន វាអាស្រ័យលើប្លង់មេនៃគម្រោងអភិវឌ្ឍមួយៗខ្លួនឯង។ ការអភិវឌ្ឍលំនៅដ្ឋានត្រូវតែពិចារណាលើរបៀបរស់នៅរបស់ប្រជាជនការធ្វើដំណើរ និងស្ថានភាពចរាចរណ៍ជារួម។ ការអភិវឌ្ឍលំនៅដ្ឋាននីមួយៗ គួរតែមានភាពសម្បូរបែបមានប្រសិទ្ធភាព និងបំពាក់ដោយអ្វីៗដែលមានភាពចាំបាច់ក្នុងជីវិត ដូច្នេះវាអាចកាត់បន្ថយតម្រូវការក្នុងការធ្វើដំណើរទៅវិញទៅមកចេញចូលទៅក្នុងកណ្តាលទីក្រុង។ ដោយឡែកសកម្មភាពពាណិជ្ជកម្មគួរកើតឡើងនៅក្នុងកណ្តាលទីក្រុង និងនៅទីតាំងជុំវិញទីក្រុងដែលតភ្ជាប់ទីក្រុងទៅតំបន់ជាយក្រុង។ តំបន់ពាណិជ្ជកម្មនៅក្នុងទីក្រុងគួរបំពេញតម្រូវការរបស់ប្រជាជនដែលកំពុងរស់នៅ និងធ្វើការនៅទីនោះ និងការធ្វើផែនការរៀបរបរស់នៅអាជីវកម្មដែលរួមបញ្ចូលទាំងធនាគារ ទីផ្សារ ការិយាល័យ សាលារៀន សារមន្ទីរ បណ្ណាល័យ ភោជនីយដ្ឋាន រោងភាពយន្ត និងផ្សារទំនើបជាមួយគ្នា។ សកម្មភាពពាណិជ្ជកម្មនៅជាយក្រុងនេះ នឹងបំពេញសម្រាប់ប្រជាជនក្នុងតំបន់ និងអ្នកដែលប្រើវាជាចំណុចឆ្លងកាត់មួយជាមួយអាជីវកម្មដូចជាសាខាតូចៗរបស់ធនាគារ អគារការិយាល័យកម្រិតទាប ផ្សារ មជ្ឈមណ្ឌលទិញទំនិញ ស្ថានីយឆ្លងកាត់ស្ថានីយចំណត និងកន្លែងលក់ដុំជាដើម។

ទន្ទឹមនឹងនេះយើងមើលឃើញមានការរីកចម្រើនគួរឱ្យកត់សម្គាល់នាពេលសព្វថ្ងៃនេះ ដោយក្នុងនោះរួមមានទីក្រុងរណប លំនៅដ្ឋាន ផ្សាររាត្រី កន្លែងហាត់ប្រាណ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធដទៃទៀត ដែលត្រូវបានរៀបចំកែលម្អ ដោយមានការតុបតែងភ្លើងពណ៌នាពេលរាត្រីការបំពាក់នូវប្រព័ន្ធបច្ចេកវិទ្យាទំនើប ដូចជាចរាចរណ៍ឆ្លាតវៃ ភ្លើងបំភ្លឺផ្លូវឆ្លាតវៃ ចំណតឆ្លាតវៃ ប្រព័ន្ធកាមេរ៉ាសុវត្ថិភាពឆ្លាតវៃ និងការគ្រប់គ្រងកាកសំណល់ឆ្លាតវៃ ដែលអាចទាក់ទាញប្រជាពលរដ្ឋបានមួយកម្រិតទៀតដែលរស់នៅទីនោះ ក៏ដូចជាភ្ញៀវ

ទេសចរណ៍ឱ្យចូលមកទស្សនា និងលេងកម្សាន្ត។ ទោះបីជាយ៉ាងនេះក្តីក៏មានបញ្ហាមួយចំនួនទៀតចំពោះការវិវត្តន៍ខ្លួនទៅជាទីក្រុងឆ្លាតវៃ។

ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ យើងខ្ញុំសូមបញ្ចេញមតិដូចតទៅៈ

- គួររៀបចំប្លង់គោលសម្រាប់ផែនការរៀបចំទីក្រុងឆ្លាតវៃនៅកម្ពុជា ឱ្យបានឆាប់ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ដើម្បីឱ្យចេញជារូបរាងនាពេលដ៏ខ្លីខាងមុខ
- ស្នើសុំអំពាវនាវដល់រាជរដ្ឋាភិបាល អាជ្ញាធរពាក់ព័ន្ធ មេត្តាបង្កើនការយកទុកដាក់ចុះត្រួតពិនិត្យការសាងសង់សំណង់ផ្សេងៗ ជាពិសេសការចូលរួម ថែរក្សាការពារបរិស្ថាន និងបំផុសស្មារតីឱ្យមានការចូលរួមក្នុងការរៀបចំក្រុងទីឆ្លាតវៃមួយនេះឱ្យទទួលបានជោគជ័យ
- បន្តរៀបចំភ្លើងលម្អតាមទីសាធារណៈ និងលើកទឹកចិត្តដល់ស្ថាប័នរដ្ឋ និងគ្រឹះស្ថានឯកជន មេត្តាសហការដើម្បីឱ្យទីក្រុងមួយនេះទៅជាទីក្រុងទំនើបនាពេលអនាគត
- បង្កើតការរកសាង និងជួសជុលនូវហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត ដូចជា ផ្លូវ សួនច្បារ ស្ពាន លំនៅដ្ឋានសាលារៀន និងមន្ទីរពេទ្យ។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់

- រដ្ឋធម្មនុញ្ញ, គ្មានលេខ, ២៤ កញ្ញា ១៩៩៣។
- ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ នស/រកម/០៦៩៩/០៩/, ២៣ មិថុនា ១៩៩៩។
- ច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, គ្មានលេខ, ១០ សីហា ១៩៩៤។
- ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ២០០១។
- ច្បាប់ស្តីពីសំណង់, លេខ នស/រកម/១១១៩/០១៩/, ០២ វិច្ឆិកា ២០១៩។
- ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌, លេខ ២៦/០១៩៦, ២៥ មករា ១៩៩៦។
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, លេខ នសរ/រកម/០៣០១/០០៥, ១៩ មីនា ២០០១។
- ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ, លេខ នស/រកម/១២៩៦/៣៦, ២៤ ធ្នូ ១៩៩៦ (ពីពេលនេះតទៅហៅថាច្បាប់បរិស្ថានឆ្នាំ១៩៩៦)។
- ច្បាប់ស្តីពីផ្លូវថ្នល់, លេខ នស/រកម/០៥១៤/០០៨, ១១ មេសា ២០១៤។
- ច្បាប់ចរាចរណ៍ផ្លូវគោក, លេខ នស/រកម/០១១៥/០០១, ៣០ ធ្នូ ២០១៤។

## អនុក្រឹត្យ

- អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងរំខានដោយសំឡេង, លេខ៤២អនក្រ.បក, ១០ កក្កដា ២០០០។
- អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ១១៣អនក្រ.បក, ២៧ សីហា ២០១៥។
- អនុក្រឹត្យស្តីពីគ្រប់គ្រងថង់ប្លាស្ទិក, លេខ១៦៨ អនក្រ.បក, ១០ តុលា ២០១៧។
- អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់, លេខ២៣៥ អនក្រ.បក, ២៥ ធ្នូ ២០១៧។
- អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់, លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧។
- អនុក្រឹត្យ៤៦ អនក្រប.បក ស្តីពីនីតិវិធីនៃការសាងសង់ប្លង់សុរិយោដី និងសៀវភៅ គោលបញ្ជីដីធ្លី, ២០០២។
- អនុក្រឹត្យលេខ៤៧ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការសុរិយោដី, ២០២០។
- អនុក្រឹត្យលេខ៤៨ អនក្រ.បក ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, ២០០២។

- អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់, ១៨ ធ្នូ ១៩៩៧។
- អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ២០ កក្កដា ១៩៩៩។

## ប្រកាស

- ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរប់សាខាកាំកុងត្រូលរាជធានី-ខេត្ត, លេខ២៣៣ព.ណបល.ប្រក, ១៤ កក្កដា ២០១៦។

## សារាចរ

- សារាចរណែនាំស្តីពីការរៀបចំគម្រោងប្លង់គោលនៅតាមខេត្ត-ក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជា, លេខ០២សរ, ១៥ មករា ១៩៩៦។
- សារាចរលេខ០២, ១៥ មករា ១៩៩៦ របស់ខុទ្ទកាល័យនៃទីស្តីការគណៈរដ្ឋមន្ត្រី។

## ផែនការណែនាំ

- ផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព, លេខ០២២ ផក, ១០ សីហា ២០១២។

## សៀវភៅ

- បណ្ឌិត អ៊ុន សកក្កដា. ២០១៩. *នីតិនគរូបនីយវិទ្យា*។

## ទស្សនាវដ្តី

- ជា, មួយគីម. ២០១៩. *អ្វីដែលអ្នកគួរយល់ដឹងអំពីទីក្រុងឆ្លាតវៃ.* ជំនួយស្មារតី, ភ្នំពេញ: មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

## គេហទំព័រ

- គេហទំព័រសុខភាពកម្ពុជា
  www.healthcambodia.com
- គណនី Facebook របស់រដ្ឋបាលខេត្តសៀមរាប
  https://www.facebook.com/SiemReap.provincial/
- គណនី Youtube របស់Construction&Property News
  https://www.youtube.com/watch?v=yByOw3VK3eQ&feature=youtu.be

# ឧបសម្ព័ន្ធរូបភាព

# មាតិកាឧបសម្ព័ន្ធរូបភាព

១. ទិដ្ឋភាពទូទៅនៃការរៀបចំក្រុងឱ្យមានសោភ័ណ្ឌភាព និងសណ្តាប់ធ្នាប់ នាបច្ចុប្បន្ននៅកម្ពុជា

២. ប្លង់គោលរាជធានីភ្នំពេញ ក្រុងបាត់ដំបង និងក្រុងសៀមរាប

៣. គម្រោងផ្សេងៗក្នុងការរៀបចំទីក្រុងឆ្លាតវៃ

## ១. ទិដ្ឋភាពទូទៅនៃការរៀបចំក្រុងឱ្យមានសោភ័ណ្ឌភាព និងសណ្ដាប់ធ្នាប់ នាបច្ចុប្បន្ននៅកម្ពុជា







សោភ័ណ្ឌភាពពេលយប់នៅ
រាជធានីភ្នំពេញ
500px
500px.com/photo/135975073




សោភ័ណ្ឌភាពនៅខេត្តសៀមរាប
CHEERS
Carlsberg




សោភ័ណ្ឌភាពនៅបាត់ដំបង
TNAOT@2GoAdventure



# ការរៀបចំចិញ្ចើមផ្លូវ







## ២. ប្លង់គោលរាជធានីភ្នំពេញ ក្រុងបាត់ដំបង និងក្រុងសៀមរាប



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនទីប្លង់គោលប្រើប្រាស់ដីក្រុងសៀមរាប ចក្ខុវិស័យឆ្នាំ២០៣៥

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ...០០៤ សរសរ...ចុះថ្ងៃ...........ខែ...........ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី...០៥...ខែ...........ឆ្នាំ២០១៨














មាត្រដ្ឋាន ១:៥៥០០០

0 0.5 1 2 3 4 គ.ម

សន្លឹកផែនទី: ១

# ប្លង់គោលប្រើប្រាស់ដីក្រុងបាត់ដំបងឆ្នាំ២០៣០

Land Use Master Plan of Battambang City, 2030





៣. គម្រោងផ្សេងៗក្នុងការរៀបចំទីក្រុងឆ្លាតវៃ

បណ្ដាញទីក្រុងវៃឆ្លាតអាស៊ាន




គម្រោងចំណតឆ្លាតវៃ
9, 850
11, 680
13, 500
15, 400
17, 200
SM8L
SM10L
SM12L
SM14L
SM16L


1st
LEVEL B1
-3.40
LEVEL B2
-6.60
6.00
5.00
8.00
8.00
8.00
8.00
8.00
8.00
8.00
5.00
6.10
66.00
1
2
3
4
5
6
7
8
9
10


P
SMART
PARKING


300m


គម្រោងភ្លើងបំភ្លឺឆ្លាតវៃ
Control and Management Center
3G /4G or WiFi / Ethernet
Sensor
Gateway
Communication with other poles
3G / 4G
No motion detected.
Trailing lights are turned off


Environment Monitoring
Intelligent Lighting
Base Station
Wi-Fi Hotspot
Surveillance Camera
LED Display
LED
EV Charging Station


គម្រោងកាម៉េរាសុវត្ថិភាពឆ្លាតវៃ
6N0X1678
Traffic Police Station
Distributed Information System
Traffic Control Server
Local Database
Information System regional Database
Data Processing Center




LIVE CRIME STATS
ALL SECTORS
MEG.
SOUTH


Smart


គម្រោងចរាចរណ៍ឆ្លាតវៃ



គម្រោងការគ្រប់គ្រងកាកសំណល់ឆ្លាតវៃ








일반쓰레기
General waste
재활용쓰레기
Recyclables only